[2] To save time, the facilitator may ask Group 1 to work on the first six months (Jan-Jun) for Battambang province and Group 2 for the last six months (Jul-Dec), Group 3 for the first six months (Jan-Jun) for Kampong Speu province and Group 4 for the last six months (Jul-Dec).

### ជំហ៊ានទី ២ ការសិក្សាទៅលើកត្តាកំណត់និងប្រូបាបនៃការព្យាករណ៍

### Step 2. Discuss the nature of deterministic and probabilistic forecasts

អ្នកសម្របសម្រួលចាប់ផ្តើមពន្យល់ពីភាពមិនច្បាស់លាស់ទាក់ទងនឹងការព្យាករណ៍ហើយបកស្រាយថាការព្យាករណ៍មិនមែនត្រឹមត្រូវរហូតនោះទេ។ ការព្យាករណ៍មានកម្រិតប្រូបាប៊ីលីតេជាក់លាក់មួយ។ ប្រសិនបើប្រូបាប៊ីលីតេនៃភ្លៀងខ្ពស់វាមានន័យថាភ្លៀងទំនងជាអាចធ្លាក់មក។ ស្រដៀងគ្នានិងនេះដែរប្រសិនបើប្រូបាប៊ីលីតេមានកំរិតទាបនោះ ភ្លៀងទំនងជាមិនអាចកើតមានទេ។

The facilitator begins by explaining the uncertainties associated with forecasts, and emphasizes that forecasts are not always correct. Forecast have certain levels of probability. If the probability of rain is high, it means rainfall is most likely to occur. Similarly, if rainfall probability is low, then rainfall is less likely to occur.

ដើម្បីពន្យល់បន្ថែមអ្នកសម្របសម្រួលណែនាំអំពីហ្គេមប្រូបាប៊ីលីតេដោយប្រើគ្រាប់ឃ្លីដែលមានពីរពណ៌ ពណ៌សបង្ហាញពីការព្យាករណ៍ត្រឹមត្រូវនិងពណ៌បៃតងបង្ហាញពីការព្យាការណ៍ត្រឹមត្រូវ ។ អ្នកសម្រួលសម្រួលប្រាប់ ឱ្យអ្នកចូលរួមចាប់យកគ្រាប់ឃ្លីចំនួន ១គ្រាប់ដោយមិនមើលពីប្រអប់ដែលមានគ្រាប់ឃ្លីពណ៌សចំនួន ៤០គ្រាប់ និងពណ៌បៃតងចំនួន ១០គ្រាប់។ អ្នកចូលរួមមើលពណ៌របស់គ្រាប់ឃ្លីរួចដាក់គ្រាប់ឃ្លីចូលក្នុប្រអប់វិញ ចំនែកឯអ្នកសម្របសម្រួលវិញត្រូវកត់ពណ៌របស់គ្រាប់ឃ្លីនោះនៅលើក្រាដាស A0 ដូចតារាងដែលបានបង្ហាញខាងក្រោម

To explain the concept further, the facilitator introduces a game of probabilities using marbles of two colors, where white indicates correct forecast and green means wrong forecast. The facilitator asks a participant to take (without looking) one marble from a container with 40 white marbles and 10 green marbles. The participant identifies the marble color then returns the marble in the same container while the facilitator notes the marble color in the flip chart, which outlines a table similar to the following.

Table 2-5. Game of probabilities

| Participant<br>អ្នកចូលរួម | White<br>ពណ៌ស | Green<br>ពត៌បៃតង |
|---|---|---|
| 1 | | |
| 2 | | |
| 3 | | |
| 4 | | |
| 5 | | |
| 6 | | |
| 7 | | |
| 8 | | |
| 9 | | |
| 10 | | |
| Total | | |
| % of Total | | |

ការចាប់យកគ្រាប់ឃ្លីនេះគឺត្រូវធ្វើងដែលរហូតដល់អ្នកចូលរួមបានលេងចំនួន ១០នាក់ បានមើលពណ៌របស់គ្រាប់ឃ្លី ។ អ្នកសម្របសម្រួលរាប់ចំនួនគ្រាប់ឃ្លីទាំងពីរពណ៌សរុប ហើយអ្នកទាំងអស់គ្នាគណនាភាគរយនៃការចាប់បានពណ៌ស និងពណ៌បៃតង ។ ជាឧទាហរណ៍ មានគ្រាប់ឃ្លីពណ៌សចំនួន ៧គ្រាប់ក្នុងចំនួនគ្រាប់ឃ្លី ១០គ្រាប់អញ្ចឹងមានន័យថាការព្យាករណ៍ត្រឹមត្រូវ ៧០%។

The process of taking and returning marbles is repeated until 10 participants have identified marble colors. The facilitator then counts the total number of white and green marbles and everybody identifies the percentage of white and green marbles against total. For instance, 7 white marbles out of 10 is 70% correct forecast.

### ជំហ៊ានទី ៣ ការពិភាក្សាជាមួយអ្នកចូលរួមពីអារម្មណ៍ក្នុការប្រើប្រាស់ការប្យាករណ៍ដែលមានប្រូបាប ៧០%

### Step 3. Discuss with participants their receptivity to use forecast with 70% probability

អ្នកសម្របសម្រួលឱ្យអ្នកចូលរួមប្រើប្រាស់ការព្យាករណ៍ រួមទាំងកម្រិតនៃប្រូបាប ភាពត្រឹមត្រូវនិងការព្យាករណ៍ដោយភាពបើកចំហដែលពួកគាត់ប្រហែលជាមានបំណងបញ្ចូលព័ត៌មាននៅក្នុងផែនការនិងការសម្រេចចិត្តរបស់ពួកគាត់។

The facilitator asks participants their openness to use forecasts, including the level of probability/accuracy/forecast skill that they may be willing to integrate the information in their plans and decisions (see Table 2-6).

**Table 2-6. Accuracy levels for multi-timescale forecasts**

| Forecast<br>ការព្យាករណ៍ | Farmer Requirements<br>តម្រូវការរបស់កសិករ | Remarks<br>ផ្សេងៗ |
|---|---|---|
| ប្រចាំថ្ងៃ Daily | | |
| ៣ថ្ងៃ 3-day | | |
| ៧ថ្ងៃ 7-day | | |
| ប្រចាំខែ Monthly | | |
| ប្រចាំរដូវ Seasonal | | |

ភាពត្រឹមត្រូវនៃការព្យាករណ៍ខុសគ្នាតាមពេលវេលាផ្សេងៗគ្នា ដែលការព្យាករណ៍រយៈពេលខ្លីវាមានភាពត្រឹមត្រូវច្រើនជាងរយៈពេលវែង ។ ការព្យាករណ៍ក៏ត្រូវបានប្រើប្រាស់ខុសៗគ្នាដែរទៅតាមប្រភេទនៃអ្នកប្រើប្រាស់។ ដូច្នេះវាពិតជាមានសារៈសំខាន់ខ្លាំងណាស់ដែលអ្នកចូលរួមបណ្តុះបណ្តាល (ឧ. អ្នកផ្សព្វផ្សាយកសិកម្មនិង កសិករដែលមានកម្រិតខុសៗគ្នា) ពិភាក្សាព័ត៌មានដែលពួកគាត់ត្រូវការពី អគ្គនាយកដ្ឋានកសិកម្ម។

Forecast accuracy differ across different timescales – short-range forecasts are more accurate than long-range forecasts. The forecasts are also used differently by various users. Therefore, it is important that training participants (i.e., extension workers and farmers at various levels) discuss their information needs and requirements from DOM.

# មេរៀនទី ៣ ការព្យាករណ៍ធាតុអាកាស និង ការទស្សទាយអាកាសធាតុ

## 3. Module Three: Weather Forecasts and Climate Outlooks

ការព្យាករណ៍ធាតុអាកាស និងការប្រមើលមើលអាកាសធាតុមានសារៈសំខាន់ណាស់សម្រាប់កសិករក្នុងការចាត់វិធានការដោះស្រាយជាបន្ទាន់ដើម្បីដោះស្រាយការប្រែប្រួលធាតុអាកាសដែលមិនបានរំពឹងទុកជាមុន ឬក្នុងការផ្លាស់ប្តូរផែនការនិងយុទ្ធសាស្ត្ររយៈពេលវែងរបស់ពួកគាត់។

Weather forecasts and climate outlooks are very important for farmers to take immediate remedies to address unexpected changes in weather or to alter their long-term plans and strategies.

## ៣.១ ការព្យាករណ៍ដែលមានរយៈពេលខុសៗគ្នា និងសេវាកម្មរបស់ DOM

### 3.1 Forecast Products and Services of DOM

នាយកដ្ឋានឧតុនិយម (DOM) គឺជាភ្នាក់ងារដែលមានកាតព្វកិច្ចសង្កេតមើល ត្រួតពិនិត្យនិងផ្តល់នូវលទ្ធផលនៃការព្យាករណ៍ និងសេវាកម្មឧតុនិយមនៅក្នុងប្រទេសកម្ពុជា។ វគ្គនេះផ្តោតសំខាន់លើសេវាកម្ម និងការព្យាករណ៍ដែលមានរយៈពេលខុសៗគ្នាពី (DOM) ។

The Department of Meteorology (DOM) is the agency mandated to observe, monitor and provide meteorological products and services in Cambodia. This session encapsulates the key services, mandates and products of DOM.

#### ៣.១.១ គោលបំណង

#### 3.1.1 Objectives

នៅចុងបញ្ចប់នៃវគ្គនេះអ្នកចូលរួមគួរតែអាចៈ

At the end of the session, participants should be able to:

ទទួលបានព័ត៌មាននៃការព្យាករណ៍ដែលមានរយៈពេលខុសៗគ្នានិងសេវាកម្មរបស់ DOM។

- List the information products and services of DOM

សិក្សាអំពីការប្រើប្រាស់សក្តានុពលនៃផលិតផលព័ត៌មានធាតុអាកាស និងអាកាសធាតុដែលមានរយៈពេលនៃការព្យាករណ៍ខុសៗគ្នានៅក្នុងផលិតកម្មកសិកម្ម។

- Discuss the potential uses of weather and climate information products in agricultural production

#### ៣.១.២ គោលបំណង

#### 3.1.2 Session Time

វគ្គនេះមានរយៈពេល ២០នាទី ។

This session takes about 20 minutes.

#### ៣.១.៣ ឧករណ៍ និងសម្ភារៈ

#### 3.1.3 Materials Needed

ក្រដាស A0 Flip charts

ហ្វឺត Marker pens

#### ៣.១.៤ ការណែនាំ

#### 3.1.4 Guide

**ជំហ៊ានទី ១ ពិភាក្សាជាមួយអ្នកចូលរួមពីការប្រើប្រាស់ការព្យាករណ៍ពី DOM**

**Step 1. Discuss with participants their current use of DOM forecasts**

អ្នកសម្របសម្រួលស្នើរឱ្យអ្នកចូលរួមនិយាយអំពីការយល់ដឹងរបស់ពួកគាត់លើការព្យាករណ៍រយៈពេលផ្សេងៗគ្នា និង និងសេវាកម្មរបស់ DOM ដែលជាបណ្តាញដែលពួកគេទទួលបានការព្យាករណ៍ និងជាអ្វីដែលពួកគាត់ប្រើព័ត៌មានការព្យាករណ៍របស់ DOM ក្នុងការធ្វើផែនការឬការសម្រេចចិត្តរបស់ពួកគាត់។ អ្នកសម្របសម្រួលកត់ចម្លើយរបស់ពួកគាត់លើក្រដាស A0 ហើយមើលថាតើពួកគាត់បានដឹងច្បាស់អំពីការព្យាករណ៍និងសេវាកម្មរបស់ DOMនិងដៃគូរពាក់ព័ន្ធរបស់ពួកគេដែរឬទេ។

The facilitator asks participants to talk about their knowledge of DOM products and services, the channels in which they access these forecasts and the ways in which they use DOM forecast products in planning or decision-making. The facilitator lists the participants’ answers in the flip chart, and notes whether participants are fully aware of DOM products and services, and their relevance.

**ជំហ៊ានទី ២ បង្ហាញពីព័ត៌មាននៃការព្យាករណ៍ធាតុអាកាស និងអាកាសធាតុ**

**Step 2. Present the various weather and climate information products of DOM**

អ្នកសម្របសម្រួលបង្ហាញពីព័ត៌មានធាតុអាកាសនិងអាកាសធាតុដែលចេញផ្សាយដោយ DOM តាមរយៈ បណ្តាញផ្សេងៗដូចខាងក្រោម:

The facilitator presents the weather and climate information products released by DOM through various channels as follows.

Table 3-1. DOM products and services

| Product/Service<br>ការព្យាករណ៍នៃរយៈពេលខុសៗគ្នា | Release Day/Time<br>ថ្ងៃ ម៉ោង ចេញផ្សាយ | Dissemination Channel<br>បណ្តាញផ្សព្វផ្សាយ | Parameters | Use<br>ការប្រើប្រាស់ |
|---|---|---|---|---|
| Nowcasts | | | | ការព្យាករណ៍ភ្លៀង រន្ទះ ព្យុះ<br>Forecasting rainfall, thunderstorm, gust |
| ប្រចាំថ្ងៃ<br>Daily | | Newspaper, TV, radio<br>កាសែត ទូរទស្សន៍ វិទ្យុ | | ដំណើរការប្រចាំថ្ងៃ<br>Day-to-day operations |
| ៧ថ្ងៃ<br>7-day | | Newspaper, TV, radio<br>កាសែត ទូរទស្សន៍ វិទ្យុ | | ការនាំចេញនាំចូល<br>Logistics planning |
| ប្រចាំខែ<br>Monthly | | Website<br>វែបសាយ | | ការគ្រប់គ្រងដំណាំ<br>Crop management |
| ប្រចាំរដូវ<br>Seasonal | | Website<br>វែបសាយ | | ផែនការដាំដុះ<br>Crop planning |

**ជំហ៊ានទី ៣ បង្ហាញផ្លូវដែលអាចបង្កើនការទាយយកនិងប្រើប្រាស់ការព្យាករណ៍របស់ DOM ដោយកសិករប្រើប្រាស់ចុងក្រោយ**

**Step 3. Discuss ways to increase access and use of DOM forecasts by end-user farmers**

បន្ទាប់ពីបង្ហាញព័ត៌មាននៃការព្យាករណ៍និងសេវាកម្មរបស់ DOM រួច អ្នកសម្របសម្រួលពិភាក្សាជាមួយអ្នកចូលរួមអំពីរបៀបដែល DOM និង MARD អាចលើកកម្ពស់ការយល់ដឹងនិងសមត្ថភាពក្នុងការប្រើប្រាស់ព័ត៌មានព្យាករណ៍ក្នុងរយៈពេលផ្សេងៗគ្នាក្នុងការធ្វើផែនការនិងការសំរេចចិត្តក្នុងការងារកសិកម្ម។

After presenting DOM's information products and services, the facilitator discusses with participants how DOM and MARD could raise awareness and capacity to use multi-timescale forecast information in farm-level planning and decision-making.

## ៣.២ ការបង្ហាញពីកម្មវិធី SESAME

## 3.2 Introduction to SESAME

RIMES បានបង្កើតឧបករណ៍ជំនួយការមួយហៅថាប្រព័ន្ធជំនាញឯកទេសសំរាប់ការផ្តល់ព័ត៌មានត្រៀមទុកជាមុនអំពីកសិឧតុនិយម (SESAME) ដែលជួញផ្តល់ការព្យាករណ៍ទាន់ពេលវេលា មានភាពសកម្មនិងពាក់ព័ន្ធដែលសមស្របសម្រាប់អ្នកប្រើប្រាស់ ។ ឧបករណ៍នេះត្រូវបានបង្កើតនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ២០១៨ ហើយវាបានជួយមន្រ្តីកសិកម្មនិងអ្នកផ្សព្វផ្សាយក្នុងការទទួលបានព័ត៌មានអាកាសធាតុ ធាតុអាកាសទៅជាការណែនាំកសិកម្មដែលអាចអោយកសិករមានការគ្រប់គ្រងធនធាននិងហានិភ័យល្អជាងមុន។ វគ្គនេះនិងពិភាក្សាអំពីឧបករណ៍ SESAME រួមមានលក្ខណៈពិសេស មុខងារនិងកម្មវិធីក្នុងប្រតិបត្តិការងារកសិកម្ម។

RIMES has developed a decision support tool called Specialized Expert System for Agro-Meteorological Early Warning (SESAME) which facilitates timely, actionable and relevant forecast based advisories for end users in the agriculture sector. The tool is customized for Cambodia in 2018 and it has been assisting agriculture officers and extension workers in automating the process of translating weather/climate information into agricultural advisories that could be provided to farmers, for informed and better management of resources and risks. This session discusses the SESAME tool, including the features, functions and application in farm-level operations.

### ៣.២.១ គោលបំណង

### 3.2.1 Objectives

នៅចុងបញ្ចប់នៃវគ្គនេះអ្នកចូលរួមគួរតែអាចៈ

At the end of the session, participants should be able to:

ស្គាល់ពីការភ្ជាប់គ្នារវាង SESAME និងអ្នកប្រើប្រាស់។

- Familiarize the SESAME user interface

កំណត់ចំនុចសំខាន់ៗដូចជាការព្យាករណ៍ និងបារ៉ាម៉ែត្រក្នុងរយៈពេលខុសៗគ្នា ព័ត៌មានដំណាំ និងការណែនាំពីការដាំដុះ

- Identify critical elements such as the multi-timescale forecasts and parameters, crop information and crop advisories

យល់អំពីសក្តានុពលរបស់កម្មវិធី SESAME និងលទ្ធផលរបស់វានៅក្នុងការធ្វើផែនការនិងការសម្រេចចិត្តក្នុងការងារកសិកម្ម។

- Appreciate the potential application of SESAME and its outputs in farm-level planning and decision-making

### ៣.២.២ រយៈពេល

### 3.2.2 Session Time

វគ្គនេះចំណាយពេលប្រហែល ៤០នាទី ។

This session takes about 40 minutes.

### ៣.២.៣ សម្ភារៈត្រូវការ

### 3.2.3 Materials Needed

ទូរស័ព្ទដែលមានប្រព័ន្ធប្រតិបត្តិការ Android Android smart phones

អ៊ីនធឺណែត Mobile data

## ៣.២.៤ ការណែនាំ

## 3.2.4 Guide

**ជំហ៊ានទី ១ ការណែនាំពីឧបករណ៍ ដែលមាននៅក្នុងកម្មវិធី SESAME ដល់អ្នកចូលរួម**

**Step 1. Introduce SESAME tool to participants**

អ្នកសម្របសម្រួលបង្ហាញពីព័ត៌មានទូទៅនៃឧបករណ៍របស់កម្មវិធី SESAME ដល់អ្នកចូលរួម បន្ទាប់មកឱ្យពួកគាត់ធ្វើការជាគូនិងទាញយកកម្មវិធីទូរស័ព្ទ **SESAME** សម្រាប់ប្រទេសកម្ពុជា។ អ្នកសម្របសម្រួលជួយអ្នកចូលរួមក្នុងការចូលទៅក្នុងឧបករណ៍និងស្គាល់ពីមុខងាររបស់វា។

The facilitator provides a general background of SESAME tool to participants, then asks them to work in pairs and download the SESAME mobile app for Cambodia. He/she assists participants in navigating through the tool and familiarizing with its functionalities.




**Figure 3-1. SESAME tool interface**

រូបភាពទី ៣.១ បង្ហាញពីឧបករណ៍សំខាន់ៗនៅក្នុងប្រព័ន្ធនេះ ។ ចំនុចនៅខាងឆ្វេងដៃមានការព្យាករណ៍ ដំណាំ ការណែនាំពីដំណាំ ទិន្នន័យ លើការផ្សព្វផ្សាយ និង មតិយោបល់ ។

Figure 3-1 shows the main components of the system. The left navigation includes dashboard for forecast/outlook, crop, crop advisory, data on dissemination and feedback panel.

**ជំហ៊ានទី ២ ការណែនាំពីឧបករណ៍សំខាន់ៗ**

**Step 2. Introduce critical elements of the tool**

ក្នុងជំហ៊ាននេះអ្នកសម្របសម្រួលពិភាក្សាអំពីធាតុសំខាន់ទាំងបីរបស់ SESAME:

១. ការព្យាករណ៍និងប៉ារ៉ាម៉ែត្រ

២ ព័ត៌មានដំណាំ និង

៣ ការណែនាំពីការដាំដុះ

In this step, the facilitator discusses the three important elements of SESAME: i) forecasts and parameters, ii) crop information, and iii) agro-advisories.

ត្រង់ផ្ទាំងការព្យាករណ៍ធាតុអាកាសមានការព្យាករណ៍រយៈពេល ៣ ថ្ងៃ រយៈពេល ១០ថ្ងៃ ប្រចាំខែនិងរដូវ។ ការព្យាករណ៍រយៈពេល ៣ ថ្ងៃរួមមានប៉ារ៉ាម៉ែត្រដូចជាទឹកភ្លៀង សីតុណ្ហភាព (អតិប្បរមា និងអប្បរមា) សំណើមនិងល្បឿនខ្យល់។ ស្រដៀងគ្នានេះដែរការព្យាករណ៍រយៈពេល ១០ ថ្ងៃរួមមាន ព័ត៌មានអំពីទឹកភ្លៀង សីតុណ្ហភាព(អតិប្បរមា និងអប្បរមា) រំហួត សំណើម ចំនួនថ្ងៃភ្លៀង ។

The weather forecast panel provides forecasts for 3 days (using weather research forecasting, WRF), 10 days (from European Center for Medium-Range Weather Forecasting, ECMWF), monthly and seasonal outlooks. The 3-day forecasts include parameters like rainfall, temperature (Tmax, Tavg, Tmin), humidity and wind speed. Similarly, the 10-day forecasts include information for rainfall, temperature (Tmax, Tmin), potential evapotranspiration (PET), humidity, number of rainy days and spell. Figure 3-2 shows a snapshot of the weather forecast panel.

ផ្ទាំងព័ត៌មានដំណាំមានបញ្ជីដំណាំ ដំណាក់កាលលូតលាស់ ការដាំដុះដំណាំ ព័ត៌មានអំពីលក្ខខណ្ឌដែលដំណាំលូតលាស់ល្អ និងប្រតិទិនដំណាំ។ រូបភាពទី ៣.៣ បង្ហាញពីរូបគម្រូនៃផ្ទាំងសម្រាប់ព័ត៌មានដំណាំ។ ផ្ទាំងទី៣ គឺបង្ហាញពីព័ត៌មាននៃការណែនាំអំពីការដាំដុះលើប៉ារ៉ាម៉ែតនៃការព្យាករណ៍ផ្សេងៗគ្នា (ឧ. ភ្លៀង សីតុណ្ហភាព សំណើម ខ្យល់ និងរំហួត) ជាមួយនិងលក្ខខណ្ឌដែលដំណាំត្រូវការ។ ការណែនាំពីការដាំដុះត្រូវបានបង្កើតឡើងដោយយោងទៅលើការរួមបញ្ចូលប៉ារ៉ាម៉ែត្រនៃការព្យាករណ៍ និង លក្ខខណ្ឌតម្រូវការរបស់ដំណាំ។ ហើយក៏មានផ្ទាំងទិន្នន័យសម្រាប់អ្នកដែលប្រើប្រាស់ និង ទទួលយកការណែនាំដែលផ្តល់ព័ត៌មាននៅក្នុងឧបករណ៍ផ្ទាល់ ។

The crop information panel provides a list of crops, the growth stages, crop activity, information on ideal conditions with which the crop grows, and the crop calendar. Figure 3-3 shows a sample view of the crop panel. The third panel on crop advisory integrates the information on various forecast parameters (i.e., rainfall, temperature, humidity, wind, evapotranspiration) with the crop's required conditions. Agro-advisories are generated based on the combination of both. There is also a data panel for users who subscribed to getting advisory alerts and notifications from the tool.



Figure 3-2. SESAME forecast panel




Figure 3-3. SESAME crop information panel

**ជំហ៊ានទី ៣ ការបង្ហាញពីកម្មវិធី SESAME នៅក្នុងការបង្កើតផែនការ និងការសម្រេចចិត្តក្នុងការងារកសិកម្ម**

**Step 3. Discuss the application of SESAME in farm-level planning and decision-making**

បន្ទាប់ពីបង្ហាញផ្នែកសំខាន់ៗនៃកម្មវិធី SESAME ដែលកម្មវិធីនេះផ្អែកលើអ៊ីនធឺណែតទាំងស្រុង អ្នកសម្របសម្រួលពិភាក្សាជាមួយអ្នកចូលរួមអំពីការអនុវត្តន៍ កម្មវិធីក្នុងការធ្វើផែនការនិងការធ្វើសេចក្តីសម្រេចចិត្តក្នុងការងារកសិកម្ម ចាប់ពីផែនការដាំដុះនិងកំណត់ពេលក្នុងការរៀបចំដី និងការសាបព្រោះដើម្បីកំណត់ពេលដាក់ជី និង ប្រមូលផល ។

After presenting the important elements of SESAME app/web-based interface, the facilitator discusses with participants the application of the app in planning and decision-making at the farm-level, from crop planning and “timing” of land preparation and sowing, to “timing” of putting fertilizers and harvesting.

# មេរៀនទី ៤ ការសង្កេតធាតុអាកាស

## 4. Module Four: Weather Observation

ធាតុអាកាស និងអាកាសធាតុគឺជាបម្រែបម្រួលបរិស្ថានដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់ការលូតលាស់និងការវិវឌ្ឍន៍របស់ដំណាំ។ ប៉ុន្តែទោះបីជាកសិករជាច្រើនដឹងពីផលប៉ះពាល់ទាំងអស់នោះក៏ដោយ ក៏ចំនេះដឹងរបស់ពួកគាត់ក្នុងការប្រើប្រាស់ព័ត៌មានធាតុអាកាសដើម្បីជួយដល់ការងារកសិកម្មក៏នៅមានកម្រិតផងដែរ។ មូលហេតុនេះបណ្តាលមកពីគ្មានឧបករណ៍សង្កេតនិងទិន្នន័យដែលជាផ្នែកមួយជួយដល់ការស្រាវជ្រាវនិងវិភាគព័ត៌មានសម្រាប់ប្រើប្រាស់នៅក្នុងវិស័យកសិកម្ម។

Weather and climate are environment variables that impact greatly on crop growth and development. But even if many agriculture workers know their impacts, there remains limited knowledge on how to utilize weather and climate information to support agriculture-related activities. One of the reasons is the unavailability observation equipment and data to support research and analysis of information for use by the agriculture sector.

## ៤.១ ដំណើរការនៃការកកើតទឹកភ្លៀង

### 4.1 Process of Rain Formation

ទឹកភ្លៀងគឺជាធាតុផ្សំនៃអាកាសធាតុមួយដ៏មានសារៈសំខាន់ជាពិសេសនៅក្នុងតំបន់ដែលពឹងផ្អែកលើទឹកភ្លៀងសម្រាប់ផលិតកម្មដំណាំ។ ទឹកភ្លៀងអាចខុសគ្នាទៅតាមពេលវេលានិងទីតាំង ជាឧទាហរណ៍វាអាចនឹងភ្លៀងនៅតំបន់ជាក់លាក់មួយហើយបន្ទាប់ពីភ្លៀងរួចវានិងមានពន្លឺថ្ងៃនៅតំបន់មួយផ្សេងទៀតក្បែរនោះ ឬបើទោះបីជាវាមានភ្លៀងនៅតំបន់ទាំងពីរក៏ដោយក៏របាយទឹកភ្លៀងនៅក្នុងមួយប្រហែលជាច្រើនជាងតំបន់មួយទៀត។ វាអាចបញ្ជាក់បានថាពីព្រោះភ្លៀងត្រូវបានបង្កើតឡើងពីទឹក(ឧ.ផ្ទៃទឹកឬពីស្លឹកឈើ) ដែលហួតនិងក្លាយជាពពកដែលផ្លាស់ប្តូរអាស្រ័យទៅលើកន្លែងដែលមានខ្យល់បក់ ។ ចរន្តខ្យល់នៅក្នុងបរិយាកាសនាំយកទឹកដែលហួតទៅផ្នែកផ្សេងៗនៅក្នុងបរិយាកាស ។ នៅពេលដែលមានលក្ខខណ្ឌសមស្រប ទឹកហួតធ្លាក់ចុះមកលើផ្ទៃដី ឬមហាសមុទ្រវិញជាទម្រង់ដំណក់ទឹកភ្លៀង។ ភ្លៀងធ្លាក់ដល់ផ្ទៃផែនដីអាចត្រូវបានស្រូបដោយរុក្ខជាតិ ជ្រាបចូលក្នុងផ្ទៃដី ហូរច្រោះ និង រំហួត។

Rain is a very important climate element especially in rain fed areas which rely on rainfall for crop production. It varies considerably with time and location. For instance, it might rain in a specific area and remain sunny in another area nearby, or even if it's raining in both areas, one is probably more than the other. This is understandable because rain is formed from water (i.e., surface water or from plants' leaves) that evaporates and becomes clouds that always move depending on where the wind blows. The circulation of air in the atmosphere transport water vapor to various parts of the earth as an integral part of the earth's normal weather pattern. When conditions are suitable, water vapor is returned to the land or ocean as water droplets or rain. Rain reaching the earth's surface may be intercepted by vegetation, may infiltrate the ground surface, run off the surface or evaporate.

ភាពរប៉ាតរប៉ាយនៃព្រៃឈើគឺជាផលវិបាកនៃលក្ខខណ្ឌអាកាសធាតុនិងដី។ ជាទូទៅព្រៃឈើកាត់បន្ថយការហូរច្រោះ ធៀបទៅនិងតំបន់ដែលមិនមានព្រៃឈើ ។ កាលណាព្រៃឈើកាន់តែក្រាស់ ទឹកកាន់តែច្រើនស្តុកកាន់តែច្រើនដើម្បីកាត់បន្ថយការហូរច្រោះនៅក្នុងរដូវប្រាំង ។

The distribution of forests is a consequence of climate and soil conditions. Forests generally decrease surface runoff compared to areas with lesser/shorter or without vegetation. The denser the forest, the more water can be retained and the greater the potential for increased dry season flows.

#### ៤.១.១ គោលបំណង

#### 4.1.1 Objectives

នៅចុងបញ្ចប់នៃវគ្គនេះអ្នកចូលរួមគួរតែអាច៖

At the end of the session, participants should be able to:

ស្វែងយល់ពីដំណើរការនៃការបង្កើតទឹកភ្លៀង។

- Understand the process of rain formation

ដឹងពីសារៈសំខាន់នៃព្រៃឈើក្នុងការស្តុកទឹកភ្លៀង។

- Recognize the importance of forests in retaining rainwater

### ៤.១.២ រយះពេល

### 4.1.2 Session Time

វគ្គនេះចំណាយពេលប្រហែល ៤៥នាទី។

This session takes about 45 minutes.

### ៤.១.៣ សម្ភារះដែលត្រូវការ

### 4.1.3 Materials Needed

ចង្រ្កាន Small stove
ឆ្នាំងដែលដាក់ទឹកបាន ១លីត្រ Pan containing 1 liter of water
សន្លឹកដែករាងចតុកោណចំនួន ២សន្លឹក (50 សង់ទីម៉ែត្រ x 60 សង់ទីម៉ែត្រ) Rectangular iron sheet or foil (50 cm x 60 cm) (2 pcs)
កែវក្រិតសម្រាប់វាស់ទឹក Measuring glass for water
ដុំទឹកកក Ice blocks
នាឡិកាកំណត់នាទីStop watch
សន្លឹកដែករាងចតុកោណចំនួន ២សន្លឹក (50 សង់ទីម៉ែត្រ x 60 សង់ទីម៉ែត្រ)ដែលមានប្រហោងទំហំ ១សម Rectangular iron sheet or foil (50 cm x 60 cm) with nailed holes 1 cm apart both ways
Piece of mat (50 cm x 60 cm)

### ៤.១.៣ ការណែនាំ

### 4.1.4 Guide

**ជំហ៊ានទី ១ ការពិសោធន៍លើការកកើតទឹកភ្លៀង**

**Step 1. Exercise on rain formation**

ចាប់ផ្តើមការពិសោធន៍លើការកកើតទឹកភ្លៀងដើម្បីបង្ហាញពីកត្តាជាច្រើនដែលជះឥទ្ធិពលដល់ទំហំ និង បម្រែបម្រួលទីតាំងទឹកភ្លៀង ។ អ្នកសម្របសម្រួលធ្វើតាមជំហ៊ានដូចខាងក្រោម ៖

The session starts with an experiment on rain formation to demonstrate the many factors that affect its magnitude and its spatial and temporal variability. The facilitator uses the following steps in the experiment.

ដាំទឹកដែលមាននៅក្នុងឆ្នាំង។ ដាក់ផ្ទាំងដែកដែលមានរាងចតុកោណដែលគ្មានចន្លោះ បន្ទាប់មកទៀតដាក់ ទឹកកកលើវាអោយត្រជាក់ ។ បន្ទាប់ពីប៉ុន្មាននាទីក្រោយមកទៀតត្រូវកត់សម្គាល់ថា ១. ទឹកនៅក្នុងឆ្នាំងពុះ ហើយរំហួតនឹងប្រែទៅជាចំហាយដែលប៉ះនិងបន្ទះដែកនោះ ហើយតក់ទៅជាតំណក់ទឹក ។ កំណកទឹកនៅលើបន្ទះដែកនោះត្រូវបានប្រមូលដាក់ចូលទៅក្នុងបន្ទះដែកដែលនៅក្រោមឆ្នាំង ហើយទឹកដែលនៅលើបន្ទះដែកនោះដោយប្រើប្រាស់កែវក្រិត ។ ដំណើរការនោះត្រូវបានធ្វើជាបន្ទបន្ទាប់រដូតដល់ទឹកនៅក្នុងឆ្នាំងហួតអស់(ឧ. ឆ្នាំងស្ងួតអស់រលីង) រូប ៤.១ និង ៤.២ បង្ហាញពីការតម្លើងសម្ភារះសម្រាប់ពិសោធន៍ការកកើតនៃទឹកភ្លៀង ។

Boil the water in the pan. Place above the pan the iron sheet that has no holes and cooled by ice. After a few minutes, note how i) the water in the pan boils/evaporates/turns into vapor, reaches the iron sheet, and condenses into droplets of water. Condensed water on the iron sheet is collected through a water collector under the stove and measured using the measuring glass. This is carried out continuously until the water in the pan has completely evaporated (i.e., the pan is already dry). Figures 4-1 and 4-2 show the set-up for the experiment on rain formation.




Figure 4-1. Schematic representation of the rain formation process



Figure 4-2. Demonstration on rain formulation process

ប្រៀបធៀបបរិមាណកំណកទឹក ជាមួយនិងបរិមាណទឹកដែលហួតចេញពីខ្ទះ។
Compare the volume of condensed water with the volume of water, which evaporated from the pan.

ពិភាក្សាជាមួយអ្នកចូលរួមអំពីមូលហេតុថា ហេតុអ្វីបានជាបរិមាណកំណកទឹកមិនស្មើរនឹងទឹកដែលហួតចេញពីខ្ទះ។ ចម្លើយគឺថាជាទូទៅទឹកដែលហួតទាំងអស់នោះមិនមែនក្លាយជាភ្លៀងរហូតនោះទេវាត្រូវបានបាត់បង់ដោយសារកត្តាផ្សេងៗដូចជាខ្យល់។ ពេលខ្លះកំណកទឹកអាចមានច្រើនជាងទឹកដែលហួតព្រោះកំណកទឹកនៅជុំវិញបន្ទះដែកបានមកពីទឹកកកដែលមាននៅលើសន្លឹកដែក។ មានន័យថាកំណកអាកាសអាចមកពីប្រភពផ្សេងៗនិងមានឥទ្ធិពលខ្លាំងទៅលើការកកើតទឹកភ្លៀងនៅតាមតំបន់។
Discuss with participants potential reasons why the amount of condensed water is not the same as that, which evaporated from the pan. This generally happens because not all water vapor become rain; some are lost due to other factors like wind. Sometimes, water that condenses may be more

than that, which evaporates because the vapor around the iron sheet has condensed from the ice on the iron sheet. This means that the vapor can come from other sources and have significant effect on local rain formation.

## ជំហ៊ានទី ២ ការពិសោធន៍លើគម្របព្រៃឈើ និងការហូរច្រោះ
**Step 2. Experiment on forest cover and surface runoff**

អ្នកសម្របសម្រួលប្រាប់ពីការពិសោធន៍មួយទៀតដើម្បីបង្ហាញពីព្រៃឈើដែលជួយស្តុកបរិមាណទឹកភ្លៀងនិងជាហេតុផលដែលធ្វើអោយការហូរច្រោះថយចុះ ។ អ្នកសម្របសម្រួលអនុវត្តជំហានដូចខាងក្រោម ៖
The facilitator introduces another experiment to illustrate how forests help retain the amount of rainwater and consequently limit surface runoff. The facilitator uses the following steps.

យកបរិមាណទឹកដែលបានវាស់ពីក្នុងខ្ទះរួចចាក់ចូលទៅក្នុងបន្ទះដែកអោយបានរាបស្មើរ ។ ទឹកដែលបានហូរតាមរន្ធរបស់សន្លឹកដែកប្រៀបបានជាទឹកភ្លៀង ហើយទឹកដែលបានហូរនោះត្រូវបានប្រមូលពីសន្ទះដែកមួយទៀតដែលនៅពីក្រោមបន្ទះដែលយើងចាក់ទឹកកាលពីលោកដំបូង ។ ទឹកដែលហូរចេញពីផ្ទៃសន្លឹកដែកនោះត្រូវប្រមូលម្តងទៀតហើយបរិមាណទឹកដែលប្រមូលត្រូវយកមកវាស់។ យកនាឡិកាកំណត់នាទីដើម្បីកំណត់ពេលវេលាតាំងពីពេលចាប់ផ្តើមចាក់ទឹករហូតដល់ដំណក់ទឹកចុងក្រោយ ។ ដំណើរការនេះត្រូវបានធ្វើម្តងទៀតជាមួយនឹងក្រណាត់ (ស្រដៀងក្រណាត់ជូតជើង) ដែលដាក់នៅលើផ្ទៃបន្ទះដែកនោះដែលយើងចាត់ទុកថាក្រណាត់នោះ ហើយក្រណាត់នោះវាប្រៀបដូចទៅជាព្រៃឈើអញ្ចឹង បន្ទាប់មកទឹកត្រូវបានប្រមូលនៅក្នុងដំណើរការទាំង២ ហើយនិងនាទីដែលបានកត់ត្រាដើយនាឡិកាត្រូវយកមកប្រៀបធៀបគ្នា។ រូបភាពទី ៤-៣ បង្ហាញពីដំណាក់កាលនៃការពិសោធន៍នេះ។

Take a measured amount of water in the pan and pour it into the holed iron sheet evenly. The water that passes the holed iron sheet acts as rainfall and is collected by the slanted sheet placed below. The water that flows from the slanted sheet surface is collected again and the volume of the collected water is measured. The time it takes for the last drop to reach the iron sheet surface is recorded with a stopwatch. This process is repeated with a mat placed in the slanted iron sheet on the entire surface. The mat acts as a forest. The amount of water collected in the two processes and the time it takes for the last drop to flow is then compared. Figure 4-3 shows a schematic of the experiment.




Figure 4-3. Schematic of the experiment on surface runoff in forests

អ្នកចូលរួមត្រូវពិភាក្សាអំពីលទ្ធផល
បន្ទាប់ពីនោះអ្នកសម្របសម្រួលពន្យល់ពីរបៀបដែលក្រណាត់នោះអាចស្តុកទឹកបានមុននិងដាក់វាចូលក្នុងខ្ទះវិញ។ វាបានបង្ហាញពីមូលហេតុដែលព្រៃឈើដែលអាចស្តុកទឹកយ៉ាងច្រើននៅក្នុងដី និងរក្សាទឹកនោះដើម្បីប្រើប្រាស់បាននៅរដូវប្រាំង។
Participants are asked to discuss the results. After which, the facilitator explains how the mat can hold water, before releasing it into the pan. This shows how forests help retain more water in the soil and make it available during the dry season.

## 4.2 Field Visit to Weather Station

ដំណើរទស្សនកិច្ចនៅស្ថានីយ៍ព្យាការណ៍ធាតុអាកាស
មានគោលបំណងចង់បង្ហាញពីសម្ភារៈផ្សេងៗដែលត្រូវបានប្រើប្រាស់ក្នុងការវាស់ធាតុរបស់ធាតុអាកាស និងអាកាសធាតុ ។ ការធ្វើទស្សនកិច្ចនេះក៏ផ្តោតសំខាន់ទៅលើសារៈសំខាន់នៃទិន្នន័យស្រាវជ្រាវ និង វិភាគ សម្រាប់ការផ្តល់ជូនព័ត៌មាន និង ការណែនាំសម្រាប់ វិស័យកសិកម្ម ។
The visit to a weather station aims to introduce different types of equipment that can be used to measure various elements of weather/climate. The visit also highlights the importance of observation data in research/analysis, for the provision of information and guidance for the agriculture sector.

### 4.2.1 Objectives

នៅចុងបញ្ចប់នៃវគ្គនេះអ្នកចូលរួមគួរតែអាចៈ
At the end of the session, participants should be able to:
កំណត់ឧបករណ៍វាស់អាកាសធាតុសំខាន់ៗដូចជារង្វាស់ទឹកភ្លៀងនិងទែម៉ូម៉ែត្រ
- Identify important weather measurement equipment like rain gauge and thermometer

ស្វែងយល់ពីសារៈសំខាន់នៃទិន្នន័យព្យាការណ៍
- Understand the importance of observation data

សង្កេតមើលលក្ខខណ្ឌនៅក្នុងតំបន់ដោយផ្អែកលើបទពិសោធន៍និងការប្រើប្រាស់ឧបករណ៍ដែលអាចធ្វើបានយ៉ាងងាយស្រួលដោយប្រើវត្ថុដែលមាននៅក្នុងស្រុកឬតំបន់
- Observe local conditions based on experience and using equipment that can be easily made using local materials

### ៤.២.៣ រយៈពេល
### 4.2.2 Session Time

វគ្គនេះមានរយៈពេល ៩០នាទី។
This session takes about 90 minutes.

### ៤.២.៣ ឧបករណ៍ដែលត្រូវការ
### 4.2.3 Materials Needed

ឧបករណ៍ ( តម្រង់ទឹកភ្លៀង)
Equipment (e.g., rain gauge, etc)

### ៤.២.៤ ការណែនាំ
### 4.2.4 Guide

#### ជំហ៊ានទី ១ បង្ហាញពីឧបករណ៍ព្យាករណ៍សំខាន់ៗ និងមុខងាររបស់ឧបករណ៍នីមួយៗ
**Step 1. Show critical observation equipment and their functions**

អ្នកសម្របសម្រួលធ្វើការទាក់ទងជាមួយនិងអ្នកដែលធ្វើការនៅក្នុងស្ថានីយ៍ដើម្បីណែនាំពីស្ថានីយ៍ និងឧបករណ៍ដែលប្រើប្រាស់នៅក្នុងការព្យាករណ៍ ។
ការធ្វើដំណើរទស្សនកិច្ចនេះត្រូវតែផ្តោតលើឧបករណ៍ដែល ប្រើប្រាស់ក្នុងការវាស់ប៉ារ៉ាម៉ែត្រ ដែលអាចមានប្រយោជន៍ចំពោះវិស័យកសិកម្មដូចជាទឹកភ្លៀង សីតុណ្ហភាព សំណើមដី សំណើម សម្ពាធខ្យល់។

The facilitator coordinates with the local observer in the weather station for the latter to provide a brief tour of the station and equipment. The orientation must focus on equipment used to measure parameters useful to agriculture such as rainfall, temperature, soil moisture, humidity, wind pressure.

អ្នកជំនាញធ្វើការនៅក្នុងស្ថានីយ៍
ត្រូវបង្ហាញពីវិធីសាស្ត្រក្នុងការព្យាករណ៍តាមបែបបុរាណទៅដល់សិក្ខាកាមផងដែរ។
ឧទាហរណ៍សិក្ខាកាមអាចពិភាក្សាជាមួយអ្នកធ្វើការនៅក្នុងស្ថានីយ៍អំពីដំណើរការនៃការសង្កេតមើល
ពពកផ្សេងៗដើម្បីទស្សទាយភ្លៀង។
The local observer also discusses with the participants traditional methods of forecasting. For instance, participants may discuss with the local observer the process of observing various cloud types to forecast rainfall.

## ជំហ៊ានទី ២ ការពិភាក្សាអំពីទិន្នន័យទឹកភ្លៀងដែលមាននៅក្នុងស្ថានីយ៍

**Step 2. Discuss observed data available in the station**

អ្នកធ្វើការនៅក្នុងស្ថានីយ៍ពិភាក្សាជាមួយអ្នកចូលរួមពីទិន្នន័យដែលមាននៅក្នុងស្ថានីយ៍ ការរក្សាទុកឯកសារ និងការប្រើប្រាស់ទិន្នន័យនោះក្នុងការព្យាករណ៍ក៏ដូចជាការស្រាវជ្រាវ។ អ្នកសម្របសម្រួលត្រូវតែបញ្ជាក់ ថាបើគ្មានទិន្នន័យទេវាពិបាកក្នុងការវិភាគនៃការកើនឡើងឬថយចុះ ការវិវឌ្ឍន៍ ការព្យាករណ៍ ឬការធ្វើការទស្សទាយអាកាសធាតុណាស់ ។
The local observer discusses with participants the observation data available in the station, how this was archived, and continuously used in forecasting as well as research. The facilitator must emphasize that without observation data, it is difficult to conduct analysis of climate trends, develop/verify forecasts and/or make high-resolution projections.

## ជំហ៊ានទី ៣ បង្ហាញពីរបៀបបង្កើតតម្រង់ទឹកភ្លៀងសាមញ្ញ

**Step 3. Demonstrate ways to fabricate a simple rain gauge**

អ្នកធ្វើការនៅក្នុងស្ថានីយនិងអ្នកសម្របសម្រួលបង្ហាញដល់អ្នកចូលរួមទាំងអស់ពីការបង្កើតរង្វាស់ទឹកភ្លៀងដ៏សាមញ្ញដោយប្រើប្រាស់វត្ថុធាតុដើមដែលមាននៅក្នុងភូមិ ។ ការមានរង្វាស់ទឹកភ្លៀងនៅក្នុងកសិដ្ឋានគឺមានសារៈសំខាន់ក្នុងការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការព្យាករណ៍ទឹកភ្លៀង។ វាក៏ជួយកសិករក្នុងការតាមដានទឹកភ្លៀងក្នុងតំបន់ផងដែរ។ សូមមើលឧបសម្ព័ន្ធ D សម្រាប់ព័ត៌មានបន្ថែមនិងការណែនាំ។
The local observer and facilitator may demonstrate to participants how to develop a simple rain gauge using locally available materials. Having a rain gauge in the farm is important in verifying the accuracy of rainfall forecasts. This also helps farmers monitor local rainfall. Please see Appendix D for more information and guidance.

## 5. Module Five: Weather and Cropping Strategies

ការព្យាករណ៍ធាតុអាកាស និង ធាតុអាកាសមានសារៈសំខាន់ណាស់ក្នុងការរៀបចំផែនការនិងយុទ្ធសាស្ត្រដាំដុះ ។ កសិករដែលធ្លាប់ដាំដុះតាមបែបប្រពៃណីចាប់ផ្តើមការរៀបចំដីនៅដើមរដូវវស្សាដើម្បីអោយទាន់ពេលមានទឹកភ្លៀង ប៉ុន្តែពួកគាត់មិនរៀបចំដាំផែនការដាំដុះដែលពួកគាត់អាចប្រើផែនការនោះជាផែនការគោលសម្រាប់ការដាំដុះពេញមួយឆ្នាំនោះទេ ។ ជួនកាលកសិករមិនបានដឹងថាលក្ខខណ្ឌអាកាសធាតុនៅក្នុងពេលវេលាជាក់លាក់មួយខុសពីស្ថានភាពធម្មតានោះទេ ដូច្នេះលំនាំដាំនិងប្រតិទិននៃការដាំដុះជាទូទៅអនុវត្តមិនទាន់ពេលវេលានោះទេ។

Weather forecasts and climate outlooks are essential in the preparation of crop plans and cropping strategies. Experienced farmers traditionally start land preparation at the onset of the rainy season to maximize rainfall utilization but do not prepare a crop plan that will serve as a blueprint from which they could systematically schedule their farming activities the whole year. Also, farmers occasionally fail to recognize that the climate condition sometimes deviates from the normal so that the cropping pattern and calendar commonly practiced may not be appropriate at times.

សព្វថ្ងៃនេះការជឿនលឿននៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាបានជួយកែលម្អវិធីសាស្ត្រនិងជំនាញនៃការព្យាករណ៍ដែលជាហេតុធ្វើអោយការព្យាករណ៍របស់រដូវនីមួយៗ បានទាន់ពេលវេលាយ៉ាងល្អ។ ក្នុងហេតុផលនេះការប្រព្យាការណ៍អាកាសធាតុប្រចាំឆ្នាំអាចត្រូវប្រើប្រាស់ដើម្បីរៀបចំផែនការនិងយុទ្ធសាស្ត្រដាំដុះដើម្បីចៀសវាងនិងកាត់បន្ថយការបាត់បង់ឬខូចខាតដំណាំ។

Recent advances in science and technology helped improve the method and skill of forecasting so that seasons can be forecasted in advance quite well. For this reason, climate outlooks can be considered when designing crop plans and strategies to avoid and/or reduce crop loss or damage.

## ៥.១ ធាតុអាកាស និងផែនការនៃការដាំដុះ

### 5.1 Weather and Cropping Plan

កសិករអាចអនុវត្តការវិភាគសាមញ្ញអំពីព័ត៌មានអាកាសធាតុនិងការព្យាករណ៍តាមរដូវ។ ផែនការនិងប្រតិទិនដាំដុះដែលអាចជួយដល់ការប្រើប្រាស់ទឹកភ្លៀងនិងកាត់បន្ថយការប្រើប្រាស់ធារាសាស្ត្រអាចត្រូវបានរៀបចំដោយប្រើប្រាស់ព័ត៌មាន ទឹកភ្លៀងធម្មតា (ឧ. បរិមាណទឹកភ្លៀងមធ្យមក្នុងរយៈពេល ៣០ឆ្នាំ) និងបរិមាណទឹកភ្លៀងដែលត្រូវបានព្យាករណ៍នៅក្នុងរដូវ តម្រូវការទឹករបស់ដំណាំ និងរយៈពេលនៃការដាំដុះ។

Farmers can perform a simple analysis of climate information and seasonal outlook. A cropping plan and calendar that would maximize rainfall utilization and minimize irrigation application can be prepared using information on normal rainfall (i.e. average rainfall amount over the 30-year period) and the forecasted rainfall amount for a given season vis-à-vis the crops’ water requirement and growing period.

### ៥.១.១ គោលបំណង

### 5.1.1 Objectives

នៅចុងបញ្ចប់នៃវគ្គនេះអ្នកចូលរួមគួរតែអាចៈ

At the end of the session, participants should be able to:

ដឹងពីសារៈសំខាន់នៃផែនការដាំដុះដើម្បីប្រើប្រាស់ទឹកភ្លៀងឱ្យបានច្រើន និងកាត់បន្ថយការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រឱ្យតិចជាងមុន។

- Recognize the importance of the crop plan to maximize rainfall utilization and minimize irrigation application

រៀបចំលំនាំ និងប្រតិទិននៃការដាំដុះដោយប្រើ parallelogram ។

- Prepare a cropping pattern and calendar using a cropping parallelogram[3]

### ៥.១.២ ពេលវេលា

### 5.1.2 Session Time

វគ្គនេះមានពេលប្រហែល ៦០ នាទី។

This session takes about 60 minutes.

### ៥.១.៣ សម្ភារៈត្រូវការ

### 5.1.3 Materials Needed

ទិន្នន័យទឹកភ្លៀងរយៈពេល ១០ ថ្ងៃ។

10-day rainfall data

តារាងបង្ហាញពីតម្រូវការទឹករបស់ដំណាំនិងរយៈពេលដាំដុះ។

Table showing the crop water requirements and crop growing period

ក្រដាសមានបែងចែកក្រឡា

Graphing paper

សន្លឹកប្លាស្ទិកថ្លាដែលមានបន្ទាត់បញ្ឈរនិងផ្តេកស្រដៀងនឹងក្រដាសបែកចែកក្រឡា។

Transparent plastic sheet with vertical and horizontal lines similar to the graphing paper

ហ្វឺត

Permanent marker

### ៥.១.៤ ការណែនាំ

### 5.1.4 Guide

**ជំហ៊ានទី១ បង្កើតលំនាំ និងប្រតិទិនដាំដុះ**

**Step 1. Develop a cropping pattern and crop calendar**

អ្នកសម្របសម្រួលបង្ហាញកសិករពីដំណើរការនៃការធ្វើលំនាំ និង ប្រតិទិនដាំដុះ ដោយការប្រើប្រាស់ព័ត៌មានភ្លៀងធ្លាក់កម្រិតធម្មតា (ឧ. បរិមាណទឹកភ្លៀងជាមធ្យមនៅក្នុងរយៈពេល ៣០ឆ្នាំ) និងភ្លៀងធ្លាក់ដែលបានព្យាករណ៍ ។ អ្នកចូលរួមត្រូវបែងចែកជាក្រុមដែលមាន ៦នាក់ក្នុង១ក្រុម ។ អ្នកចូលរួមត្រូវបង្កើតតារាងតាម រូប ៥.១ សម្រាប់ហ៊ីស្តូក្រាម ១០ថ្ងៃ តារាង ៥.១ សម្រាប់ជាគម្រូតម្រូវការទឹកសម្រាប់ដំណាំដែលបានជ្រើសរើសហើយ និង រូប៥.២ សម្រាប់ Parallelogram

Using information on normal rainfall (i.e. average rainfall amount over the 30-year period) and forecasted rainfall, the facilitator demonstrates to farmers the process for developing a cropping pattern and crop calendar. Participants are divided into sub-groups with maximum 6 people per group. They are asked to accomplish the following (please refer to Figure 5-1 for the 10-day histogram, Table 5-1 for sample water requirement of selected crops, and Figure 5-2 for a sample parallelogram).

១. រៀបចំទិន្នន័យទឹកភ្លៀងហ៊ីស្តូក្រាមសម្រាប់រយៈពេល ១ឆ្នាំដែលអាចជាភ្លៀងធ្លាក់កម្រិតធម្មតា និងភ្លៀងដែលបានព្យាករណ៍ដោយប្រើក្រដាសដែលមានបែងចែងក្រលា

i. Prepare a rainfall data chart (histogram) for 1-year period normal and forecasted rainfall using the graphing paper.

---

[3] A cropping parallelogram is a simple instrument/geometric tool that can be used to test a potential cropping pattern, sequence or area to be cultivated versus available water supply.
Parallelogram គឺជាឧបករណ៍ ធរណីមាត្រដ៏សាមញ្ញមួយដែលអាចប្រើដើម្បីធ្វើតេស្តលំនាំដាំដុះ ឬ តំបន់ដែលត្រូវដាំដុះធៀបនឹងការផ្គត់ផ្គង់ទឹក ។

២.គូសបន្ទាត់ដេកនៅក្នុងក្រដាសថ្លាដែលមានប្រវែងស្មើរនិងរយៈពេលនៃការដាំដុះនៃដំណាំដែលបានជ្រើសរើសនៅក្នុងតម្លៃស្រដៀងទៅនិងតារាងទឹកភ្លៀង ។

ii. Draw a horizontal line in a transparent plastic sheet with a length equivalent to the growing period of the selected crops at similar scale as the rainfall chart.

៣.គូសបន្ទាត់ឈរជាកម្ពស់ដែលស្មើរនិងបរិមាណទឹកដែលដំណាំត្រូវការនៅក្នុងរដូវដាំដុះនៅក្នុងតម្លៃប្រហែលនិងតារាងទឹកភ្លៀង ។

iii. Draw a vertical line with a height equal to the average crop water requirement in a season at a scale similar to the rainfall chart.

៤. បំពេញតារាង Parallelogram ដោយគូសលើផ្នែក២ ផ្សេងទៀត

iv. Complete the parallelogram by drawing the remaining two sides.

៥. ធ្វើតាមដំណើរការដដែលនៅក្នុងការបង្កើត Parallelograms ដំណាំសម្រាប់ការដាំដុះលើកទី ២ និង ទី៣

v. Follow the same procedure in constructing the cropping parallelograms for the second and third cropping.




**Figure 5-1. Histogram of annual 10-day rainfall of Battambang and Kampong Speu**

Table 5-1. Sample crop water requirement and growing period of selected crops[4]

| | Crop<br>ដំណាំ | Growing Period (days)<br>រយៈពេលដាំដុះ | Average Daily Water Requirement (mm)<br>តម្រូវការទឹកប្រចាំថ្ងៃជាមធ្យម | Total Crop Water Requirement (mm)<br>តម្រូវការទឹកសរុប |
|---|---|---|---|---|
| **Sample from the Philippines គម្រូពីប្រទេសហ្វីលីពីន** | | | | |
| 1 | ម្រេច<br>Pepper | 70 | 3.3 | 231 |
| 2 | ឆៃថាវ<br>Radish | 60 | 3.3 | 180 |
| 3 | Squash | 90 | 5.1 | 460 |
| 4 | ប៉េងប៉ោះ<br>Tomato | 110 | 4.2 | 460 |
| 5 | ស្ពៃក្តោប<br>Cabbage | 60 | 6.0 | 360 |
| 6 | ម្រះ<br>Bitter Gourd | 100 | 4.0 | 400 |
| 7 | ពោតបារាំង<br>Okra | 100 | 4.7 | 470 |
| 8 | ខ្ទឹមបារាំង<br>Onion | 100 | 4.8 | 480 |
| 9 | ដំឡូងបារាំង<br>Potato | 110 | 4.5 | 495 |
| 10 | ខ្ទឹមស<br>Garlic | 120 | 2.2 | 264 |
| 11 | ត្រប់<br>Eggplant | 150 | 4.8 | 720 |
| 12 | ពោទ<br>Corn/Maize | 110 | 5.5 | 650 |
| 13 | ស្រូវ<br>Rice | 120 | 10.0 | 1200 |
| 14 | សណ្តែកខៀវ<br>Mung bean | 70 | 4.4 | 310 |
| 15 | សណ្តែកសៀង<br>Soy bean | 110 | 4.8 | 530 |
| **Sample from Tamil Nadu, India** | | | | |
| 1 | ស្រូវ<br>(Rice) | 110 | 11.36 | 1250 |
| 2 | ពោត<br>(Maize) | 360 | 6.11 | 2200 |
| 3 | Sorghum | 105 | 4.86 | 510 |
| 4 | Kambu (Bajra) | 105 | 4.76 | 500 |
| 5 | Ragi | 100 | 5.00 | 500 |
| 6 | សណ្តែកដី<br>Ground Nut | 95 | 3.26 | 310 |
| 7 | ផ្កាឈូករ័ត្ន<br>Sunflower | 165 | 3.64 | 600 |
| 8 | ល្ង<br>(Sesame) | 65 | 4.31 | 280 |
| 9 | សណ្តែកសៀង<br>Soybean | 85 | 3.76 | 320 |
| 10 | អំពៅ | 85 | 1.76 | 150 |

[4] Data from this table is based on information from the Philippines and Tamil Nadu Agriculture University (http://agritech.tnau.ac.in/agriculture/agri_irrigationmgt_waterrequirements.html). Cambodia's Ministry of Agriculture and Rural Development (MARD) may have different values.

| | Crop<br>ដំណាំ | Growing Period (days)<br>រយៈពេលដាំដុះ | Average Daily Water Requirement (mm)<br>តម្រូវការទឹកប្រចាំថ្ងៃជាមធ្យម | Total Crop Water Requirement (mm)<br>តម្រូវការទឹកសរុប |
|---|---|---|---|---|
| | (Sugarcane) | | | |
| 11 | កប្បាស<br>(Cotton) | 110 | 4.09 | 450 |
| 12 | G.Gramm | 70 | 3.6 | 250 |
| 13 | B.Gramm | 70 | 3.6 | 250 |




រូបទី ៥.២ គម្រូ Parallelogram នៃខេត្តបាត់ដំបង
**Figure 5-2. Sample parallelogram for Batambang**

**ជំហ៊ានទី២ ពិភាក្សាអំពីភាពទាក់ទងនៃផែនការដាំដុះ**

**Step 2. Discuss the relevance of crop planning**

អ្នកសម្របសម្រួលសួរអ្នកចូលរួមដើម្បីបានចម្លើយខ្លីដូចខាងក្រោម

The facilitator asks participants to brainstorm on the following.

១. តើលំនាំ និងប្រតិទិននៃការដាំដុះអ្វីដែលសមស្របបំផុតនៅក្នុងលក្ខខណ្ឌអាកាសធាតុធម្មតា ។

i. What is the most appropriate cropping pattern and calendar under normal conditions?

២.តើមានកត្តាអ្វីខ្លះដែលជះឥទ្ធិលទៅលើលំនាំ និងប្រតិទិនដាំដុះ?

ii. What other factors influence the cropping pattern and calendar?

៣.តើមានទឹកជំនន់ជន់លិចឬទេក្នុងកំឡុងពេលរដូវវស្សា នៅពេលដែលទឹកច្រើនពេក ? តើអ្នកមានយុទ្ធសាស្ត្រអ្វីខ្លះក្នុងការដោះស្រាយបញ្ហានេះ?

iii. Is there potential for flooding during the rainy season when water is “too much”? What strategies do you use to address the problem?

៤.តើអាចមានការខ្វះខាតទឹកដែលឬទេក្នុងកំឡុងរដូវប្រាំង? តើអ្នកមានយុទ្ធសាស្ត្រអ្វីខ្លះដើម្បីដោះស្រាយបញ្ហានេះ?

iv. Is there possibility of water shortage during the dry season? What strategies do you use to address the problem?

៥.តើអ្នកមានផែនការដាំដុះ និងយុទ្ធសាស្ត្រដាំដុះផ្សេងៗដែរឬទេដើម្បីបង្កើនការប្រើប្រាស់ទឹកភ្លៀង និងកាត់បន្ថយការប្រើប្រាស់ការស្រោចស្រព។

v. Do you have alternative cropping plans and/or planting strategies to maximize rainfall utilization and minimize irrigation?

## ៦.មេរៀនទៅ ៦៖ តម្រូវការទឹករបស់ដី

## 6. Module Six: Soil Water Balance

ទឹកភ្លៀងគឺជាប្រភពទឹកដ៏សំខាន់សម្រាប់ការដុះលូតលាស់របស់ដំណាំ ប៉ុន្តែបើមានភ្លៀងធ្លាក់ច្រើននោះដំណាំក៏មិនអាចស្រូបយកអស់ដែរ ដោយមានមួយផ្នែកត្រូវបានហួតចូលទៅក្នុងបរិយាកាស និងសល់ពីនេះហូរចូលទៅកាន់ស្ទឹង ទន្លេ និងសមុទ្រ។ ប្រសិនបើប្រព័ន្ធរំដោះទឹកមិនមានលក្ខណៈល្អប្រសើរទេនោះ បរិមាណទឹកភ្លៀងដែលលើសនឹងមានការកើនឡើង ហើយបង្ករទៅជាទឹកជំនន់។ ម្យ៉ាងវិញទៀត នៅរដូវប្រាំងដែលមានភ្លៀងធ្លាក់តិចតួច នោះនឹងធ្វើឲ្យដីស្ងួតដោយសារតែមានរំហួតទឹកចេញពីដី។ បើគ្មានការស្រោចស្រព ដំណាំនឹងរងការបំផ្លាញដោយភាពរាំងស្ងួត។

Rainfall is the main source of water for crops.  But much of the rainwater cannot be used by plants. Some evaporate back to the atmosphere and others flow to rivers and eventually to the sea. If the drainage system is not good and there is excess rainfall, water will accumulate and eventually result in flooding. On the other hand, during the dry season when rainfall is rare, the water that evaporates will come from the soil so that the land will eventually become dry. Without irrigation, plants will suffer from drought.

### ៦.១ តម្រូវការទឹកសម្រាប់ដី

### 6.1 Soil Water Balance

តម្រូវការទឹកសម្រាប់ដី គឺជាបរិមាណនៃការផ្គត់ផ្គង់ទឹកទៅក្នុងដីតាមរយៈ ទឹកភ្លៀង ការស្រោចស្រព ដើម្បីបំពេញទៅឲ្យដី ដោយរួមបញ្ចូលទាំងទឹកដែលដំណាំស្រូបយក រំហួត និងទឹកដែលបានហូរចេញ។ ការវិភាគតុល្យភាពទឹកសម្រាប់ដីនៅក្នុងស្រែ គឺគ្រាន់តែជាដំណើរការនៃគណនាបរិមាណទឹកនៅក្នុងប្រព័ន្ធមួយប៉ុណ្ណោះ ដោយធ្វើការកំណត់៖ i) លំហូរចូលនៃទឹកភ្លៀង ឬ/ ការស្រោចស្រព ii) លំហូរចេញវិញតាមរយៈ រំហួត ការហូរចេញនៅខាងលើផ្ទៃដី ជម្រាប និង iii) ការផ្លាស់ប្តូរនូវប្រព័ន្ធរក្សាទុក (រូបភាព ៦-១ និង ៦-២) ។

Water balance is the balance between the amount of water supplied to the land through rain and irrigation versus the amount of water used to fill the soil with water including water used by crops and lost either through evaporation or runoff. The analysis of field water balance is simply a process of accounting the volume of water within a system, that is, identifying the i) inflows from rainfall and/or irrigation, ii) outflows through evapotranspiration, surface runoff, seepage and percolation, and iii) change in storage within the system (see Figures 6-1 and 6-2).




Figure 6-1. Water balance in flooded fields (left) versus dry fields (right)[5]

[5] In areas without standing water, moisture within the root zone need to be maintained to ensure plant growth.

បរិមាណនៃតម្រូវការទឹកគឺ កំពស់ទឹកភ្លៀង + ការស្រោចស្រព = រំហួត + ជម្រាប + ការបង្ហូរទឹក + ការផ្លាស់ប្តូរស្ថានភាពទឹក
The water balance concept can be expressed as Rainfall (Rf) + Irrigation (Ir) = Evapotranspiration (Et) + Seepage and Percolation (S&P) + Drainage (D) + Change in Water Status (ΔS).



Figure 6-2. Water balance concept

រំហួតពីដី និងដំណាំយើងហៅថារំហួតកម្ម (**ETP**) អត្រាកម្រិតនៃការហួតទឹក គឺប្រហែល ៥មម ក្នុងមួយថ្ងៃ ឬ ១៥០មម ក្នុងមួយខែ។ ប្រសិនបើកម្រិតទឹកភ្លៀងប្រចាំខែតិចជាង ១៥០មម នោះទឹកក្នុងដីគឺគ្រប់គ្រាន់សម្រាប់តែរំហួតប៉ុណ្ណោះ។ តែបើកម្រិតទឹកភ្លៀងច្រើនជាង ១៥០មម នោះបរិមាណទឹកដែលលើស និងត្រូវហូរចេញទៅកាន់ ស្ទឹង ទន្លេតាមប្រព័ន្ធបង្ហូរ។ ជាការពិតណាស់ នៅរដូវភ្លៀងបរិមាណទឹក គឺមានច្រើន តែប្រព័ន្ធរំដោះទឹកមិនមានគ្រប់គ្រាន់នោះទេ ដែលជាហេតុបង្ករឲ្យមានទឹកជំនន់ ដើម្បីរក្សាទឹកទុកក្នុងស្រែគឺត្រូវលើកភ្លឺ ឬទំនប់។ ប៉ុន្តែសម្រាប់ការដាំដុះលើដីស្ងួត បន្ទាប់ពីការជ្រាបចូលក្នុងដីគ្រប់គ្រាន់ហើយ បរិមាណដែលលើសគឺហូរទៅតាមខ្សែទឹក។
នៅរដូវប្រាំងបើភ្លៀងធ្លាក់មិនគ្រប់គ្រាន់បំពេញតម្រូវការសម្រាប់ដំណាំដុះលូតលាស់ ដីប្រែជា ស្ងួត។ នៅពេលដែលមានភ្លៀងធ្លាក់ដំបូងនៅរដូវវស្សាបន្ទាប់
សមត្ថភាពផ្ទុកទឹករបស់ដី(ប្រែប្រួលទៅតាមប្រភេទដី)
នៅជិតតំបន់ឫសរបស់ដំណាំគឺទទួលបានទឹកមុនគេ
បន្ទាប់មកវានិងជ្រាបចូលទៅក្នុងស្រទាប់ដីខាងក្រោម។
ទឹកជំនន់នឹងកើតមាននៅពេលដែលកម្រិតទឹកភ្លៀងមានការកើនឡើង។
Evaporation from land and plants is called evapotranspiration (ETP). Potential rate of evapotranspiration is about 5mm per day or 150mm per month. If the monthly rainfall is less than 150mm, the soil's water is used to compensate the need for evapotranspiration. If the monthly rainfall is more than 150mm, then the excess will flow back to rivers through the drainage system. Indeed, during the rainy season when there is excess rainfall and the drainage is not big enough to tap the water, flooding may occur. In flooded fields, this is being contained and controlled through bunds or levees. But in dry land cultivation, after satisfying soil infiltration this may result to runoff flowing to streams and their tributaries. During the dry season when rainfall is not enough to satisfy crop water requirements, the soils become dry. With the first drop of rain at the onset of the next rainy season, the soil's water holding capacity (which varies according to soil types) within the root zone is first satisfied and then rainwater percolates deeper. Flooding may again occur when there is excess rainfall.

### ៦.១.១ គោលបំណង

### 6.1.1 Objectives

នៅពេលបញ្ចប់សិក្ខាកាមនឹង៖
At the end of the session, participants should be able to:

- យល់ពីសារសំខាន់របស់ទឹក និងដីសម្រាប់ការដុះលូតលាស់របស់ដំណាំ
    - Understand the importance of water and soil elements on plant growth and development
- ពន្យល់ពីតម្រូវការទឹករបស់ដី
    - Explain the water balance concept
- ធ្វើការប៉ាន់ស្មានពីតម្រូវការទឹកស្រោចស្រព ក៏ដូចជាលទ្ធភាពដែលបង្ករជាទឹកជំនន់
    - Estimate irrigation requirement as well as possibility of floods

### ៦.១.២ ពេលវេលា

### 6.1.2 Session Time

មេរៀន**មាន**រយៈពេល ៦០នាទី

This session takes about 60 minutes.

### ៦.១.៣ សម្ភារៈ

### 6.1.3 Materials Needed

- ដបជ័រចំនួន ៨ (Eight plastic bottles)
- សំណាកដីសម្រាប់ដាក់ ១/៣ នៃដប **i)** ដីឥដ្ឋស្ងួត (ឧ. ដីឥដ្ឋ) តំណាងឲ្យដីស្រែស្ងួត **ii)** ស្រទាប់ដីឥដ្ឋសើម តំណាងឲ្យវាលស្រែ **iii)** ដីខ្សាច់ស្ងួត (ឧ. ដីខ្សាច់) និង **iv)** ដីខ្សាច់សើម

Soil samples enough to fill 1/3 of the plastic bottle: i) dry clayey soil (e.g. clay loam) representing dry land, ii) wet clayey soil with compacted layer representing paddy field, iii) dry sandy soil (e.g. sandy loam), and iv) wet sandy soil

- បំពង់កែវក្រិត Graduated cylinder

_ នាឡិការកំណត់ម៉ោង Timer

### ៦.១.៤ វិធីសាស្ត្រ

### 6.1.4 Guide

**ជំហ៊ានទី១៖ ការធ្វើលំហាត់ជាក្រុមទៅលើសមត្ថភាពនៃការស្តុកទឹកនៅក្នុងដី**

**Step 1. Group exercise on water holding capacity**

អ្នកសម្របសម្រួលធ្វើការ**បែ**ងចែកសិក្ខាកាមជាបួនក្រុមទៅតាមសំណាកដី **i)** ដីឥដ្ឋស្ងួត **ii)** ដីឥដ្ឋសើម **iii)** ដីខ្សាច់ស្ងួត **iv)** ដីខ្សាច់សើម។

ក្រុមនីមួយៗត្រូវរៀបចំនូវសម្ភារ**ៈ**ចាំបាច់មួយចំនួនដូចខាងក្រោម៖

The facilitator asks participants to form four groups based on the soil samples: i) dry clayey soil, ii) wet clayey soil, iii) dry sandy soils, and iv) wet sandy soil. The groups are asked to prepare the necessary materials as shown below.




រូបទី ៦.៣ ទម្រង់នៃសម្ភារៈដែលប្រើប្រាស់ទូទៅសម្រាប់លំហាត់ទៅលើតុល្យភាពទឹកនិងដី

**Figure 6-3. Typical set-up for the exercise on water balance concept**

រៀបចំដបជ័រចំនួនបួនដែលមានសំណាកដីបួនប្រភេទផ្សេងៗគ្នា។ តាមក្រុមនីមួយៗ សិក្ខាកាមធ្វើការចាក់ទឹកចូលក្នុងកម្រិតមួយជាក់លាក់ (ឧ. ៥០មល) ទៅក្នុងដប។ ពួកគេត្រូវធ្វើការអង្កេត និងកំណត់នូវបរិមាណទឹកដែលបានជ្រាបទៅក្នុងដបមួយផ្សេងទៀតដែលទ្រនៅខាងក្រោម និងត្រូវកំណត់ពេលរហូតដល់ដំណក់ចុង ក្រោយ។ សម្រាប់សំណាកដីស្ងួត ដំបូងវាមិនមានជំម្រាបនូវបរិមាណទឹកទាំងអស់ដែលបានចាក់នោះទេ គឺស្ថិតនៅក្នុងសមត្ថភាពនៃការផ្ទុកទឹករបស់ដី។ លក្ខខណ្ឌដូចគ្នានេះអាចកើតឡើងនៅក្នុងសំណាកស្រទាប់ដីដែលរឹង (ឧ. វាលស្រែ) ដែលកាត់បន្ថយលម្ហូរទឹកនៅក្នុងដី ។ ចំពោះលក្ខខណ្ឌទាំងអស់នោះ សិក្ខាកាមទាំងអស់បង្ហាញការយល់ដឹងពីការអង្កេតរបស់ពួកគាត់ និងអោយពួកគាត់គិតដល់លក្ខខណ្ឌទីវាល។

Four plastic bottles with different soils samples are prepared. In each group, participants pour water of known volume (e.g. 50 ml) into the plastic bottles. They are required to observe and measure the amount of water that percolates down into the collecting bottle and note the time until the last drop is finished. For dry soil sample, initially there might be no percolation at all as the amount of water poured is just within the water holding capacity. The same condition might happen in the sample with the compacted layer (i.e. paddy field) that minimizes soil water percolation. In all these cases, participants provide their observation and simulate them to actual field condition.

អ្នកសម្របសម្រួលឲ្យសិក្ខាកាមចាក់ទឹកក្នុងកម្រិតមួយជាក់លាក់ថែមទៀតទៅក្នុងដបសំណាកដី។ ជាថ្មីម្តងទៀត សិក្ខាកាមត្រូវធ្វើការកត់ត្រាលើពេលវេលារហូតដល់ដំណក់ទឹកចុងក្រោយ។ ក្នុងករណីនេះ បរិមាណនៃជម្រាបទឹកនឹងមានការកើនឡើង ដោយសារតែសមត្ថភាពនៃការផ្ទុកទឹកគឺគ្រប់គ្រាន់។ ស្រះទឹកគឺអាចប្រៀបបានទៅនឹងសំណាក់ដីជាមួយនិងស្រទាប់ដីក្រាំងតំណាងឱ្យវាលស្រែ។

វគ្គនេះនិងធ្វើអោយសិក្ខាកាមយល់ពីសារៈប្រយោជន៍សេដ្ឋកិច្ចនៃការព្យាករណ៍ និងជួយបង្កើនសមត្ថភាពរបស់ពួកគេក្នុងការគណនាចំនូលដោយប្រើប្រាស់ព័ត៍មានព្យាករណ៍នៅក្នុងការប្រើប្រាស់យុទ្ធសាស្រ្តក្នុងការ ដាំដុះប្រចាំរដូវ។

The session will allow participants to appreciate the economic importance of forecasts and at the same time improve their capability to calculate the economic benefit of using forecasts in formulating planting strategies in a given season.

### ១០.១ .១ គោលបំណង

### 10.1.1 Objectives

នៅចុងបញ្ចប់នៃវគ្គសិក្សាអ្នកចូលរួមនឹងអាច:

At the end of the session, participants should be able to:

រៀនពីវិធីសាស្រ្តសាមញ្ញក្នុងការវាយតម្លៃសេដ្ឋកិច្ចនៃការប្រើប្រាស់ព័ត៍មានការព្យាករណ៍ដែលបានអនុវត្តនៅក្នុងការបង្កើតយុទ្ធសាស្រ្តដាំដុះ

- Practice simple methods of assessing the economic value of using forecast information

អភិវឌ្ឍន៍សមត្ថភាពរបស់ពួកគេក្នុងការជ្រើសរើសយុទ្ធសាស្រ្តដាំដុះដ៏ល្អបំផុតដោយផ្អែកលើការវាយតម្លៃដែលបានធ្វើ។

- Make climate-informed decisions when choosing among alternative planting strategies and/or livelihoods

### ១០.១ .២ ពេលវេលា

### 10.1.2 Session Time

វគ្គនេះមានពេលប្រហែលជា ៦០ នាទី

This session takes about 60 minutes.

### 10.1.3 Materials Needed

ក្រដាស A0

Flip chart

Cardboard

ហ្វឺត ឬប៊ិច

Marker pens

ទិន្នន័យចំនាយ និងចំនូលនៃដំណាំមួយចំនួន

Cost and return data of some crops

និងចំនាយផ្សេងៗទៀតពីអ្នកចូលរួម

Alternative economic activities as identified in discussion with the participants

### ដំណើរការអនុវត្ត
### 10.1.4 Guide

### ជំហ៊ានទី១ ពិភាក្សាពីផលប៉ះពាល់សេដ្ឋកិច្ចពីគ្រោះរាំងស្ងួត ទឹកជំនន់ និងកំណត់សកម្មភាពក្នុងការបង្កើតប្រាក់ចំនូល
**Step 1. Discuss economic impacts of droughts/floods, and identify alternative income-generating activities**

ប្រូបាបនៃការព្យាករណ៍ (ឧទាហរណ៍: ប្រូបាប 80% ដែលវានឹងកើតឡើងហើយ 20% និងមិនកើតឡើង) ដែលជាធម្មតាត្រូវបានផ្ដល់ដោយភ្នាក់ងារសេវាកម្មឧតុនិយម និងជលសាស្ត្រថ្នាក់ជាតិដូចជា អគ្គនាយកដ្ឋានឧតុនិយម។ យោងទៅតាមការព្យាការណ៍តាមរយៈភ្នាក់ងារខាងលើ ខាងនាយកដ្ឋានកសិកម្មត្រូវផ្ដលើនូវការណែនាំពីការដាំដុះទៅដល់កសិករដើម្បីស្វែងរកដំណោះស្រាយកាត់បន្ថយហានិភ័យ
ហើយកិសករត្រូវតែសម្រេចចិត្តទៅលើដំណោះស្រាយតាមរយៈបទពិសោធន៍ដែលពួកគេមានពីមុនមក។
Probabilistic forecasts (e.g. 80% probability that it will occur, and 20% that it will not occur) are generally provided by national meteorological and hydrological services (i.e., Department of Meteorology in Cambodia). Based on the forecasts, concerned agencies (e.g., Department of Agriculture) provide advisories on the possible implications and mitigating measures, and farmers have the liberty to decide on their actions based on their past experiences.

អ្នកចូលរួមពិភាក្សាពីកំហាតសេដ្ឋកិច្ចដែលកសិករជាទូទៅជួបប្រទះនៅពេលដែលដំណាំពួកគេបំផ្លាញដោយគ្រោះរាំងស្ងួត នៅក្នុងរដូវវស្សា។ អ្នកសម្របសម្រួលណែនាំដល់សិក្ខាកាមក្នុងការជ្រើរើសសកម្មភាពក្នុងការប្រកបរបរផ្សេងក្រៅពីការកសិកម្ម។ វាអាចរួមបញ្ចូលទាំងការងារកម្លាំងពលកម្មនៅក្នុងសហគ្រាសណាមួយក្នុងតំបន់របស់សិក្ខាកាម ឬដូរដំណាំក្រៅពីស្រូវ (ឧ. ពោតត្រូវការទឹកតិច និងរយៈពេលខ្លី)។ អ្នកសម្របសម្រួលសរសេរជម្រើសដែលបានពិភាក្សាទៅលើក្រដាស់A0។
ជម្រើសទាំងអស់នៃត្រូវបានដាក់លេខរៀងយោងទៅលើតម្លៃសេដ្ឋកិច្ច។
Participants are asked to discuss the financial loss that farmers typically incur when their crops get affected by drought during the dry season or flood during the rainy season. The facilitator guides participants in identifying alternative livelihood activities apart from farming. This could include working as laborer in a dominant/potential industry in the participants' area (e.g. laborer in salt mining), or planting crops other than rice (e.g. maize which requires less water and/or takes shorter time to grow). The facilitator lists on the flipchart as many alternatives as the participants can give. These alternatives are then ranked according to the most economically viable.
ឧទាហរណ៍ ដំណាំរបស់កសិករត្រូវបានជន់លិចក្នុងរដូវវស្សា និងបានបំផ្លាញដោយទឹកគ្រោះរាំងស្ងួតនៅក្នុងរដូវប្រាំង។
បទពិសោធន៍នៃការខាតបង់របស់កសិករដាំស្រូវគឺសឹងតែស្មើរនិងការចំណាយសរុបក្នុងការដាំដុះ (ឧ. ធាតុចូលដូចជា គ្រាប់ពូជ, ជី ថ្នាំសត្វល្អិត ថ្លៃឈ្នួលផ្សេងៗ និងសម្ភារៈនៅក្នុងការរៀបចំដីនិងការគ្រប់គ្រងនានា)។ អ្នកសម្របសម្រួលសួរកសិករពី ៖ ១. ចំណាយសរុបលើការធ្វើស្រែនៅក្នុងផ្ទៃដីរបស់គាត់ ២. ចំនូលនិងប្រាក់ចំនេញដែលគាត់និងទទួលបានពីការធ្វើការងារផ្សេងទៀត ។ ជម្រើសទាំងអស់និងបានមកពីសិក្ខកាមយោងទៅតាមបទពិសោធន៍ឬ ព័ត៍មានពីតំបន់នីមួយៗ ។

> **Example**. Farmers' crops are flooded during the rainy season and damaged due to drought during the dry season. The loss experienced by paddy farmers is as much as their total cultivation cost (i.e., inputs like seeds, fertilizers, pesticides; labor and equipment for land preparation and management). The facilitator must ask farmers i) the total estimated cultivation cost in their area for rice production, and ii) potential net income/profit if he/she will engage in another job or profession. All alternative strategies and figures will come from participants based on their experience and/or information from their respective areas.

### ជំហ៊ានទី២ ធ្វើលំហាត់លើយុទ្ធសាស្ត្រឆ្លើយតប

**Step 2. Conduct an exercise on response strategies**

អ្នកសម្របសម្រួលបង្ហាញពីការព្យាករណ៍ទឹកភ្លៀងក្រោមកម្រិតជម្មតា និងពិភាក្សាជាមួយសិក្ខាកាមនូវដំណោះស្រាយដែលអាចទៅរួចសម្រាប់កសិករដែលធ្វើស្រែ ដែលដំណោះស្រាយទាំងអស់អាចមានបួនដូចជា **(១) មិនធ្វើស្រែឬដីទុកទំនេរចោល (២) មិនដាំស្រូវប៉ុន្តែផ្លាស់ប្តូរការងារឬវិជ្ជាជីវៈរបស់ខ្លួន (៣) មិនដាំដុះស្រូវប៉ុន្តែដាំដំណាំផ្សេងទៀត (៤) មិនអនុវត្តតាមការព្យាករណ៍ហើយនៅតែបន្តដាំស្រូវ។**

The facilitator presents a forecast of below normal rainfall and discusses with participants the possible responses of paddy farmers, all of which can generally be classified into four: i) do not plant or let the land lie fallow, ii) do not plant, and temporarily shift to another job or profession, iii) plant other crops, and iv) do not listen to or follow the forecast, and therefore keep planting (refer to the section on sample exercises for more information and guidance).

បន្ទាប់មកទៀតអ្នកសម្របសម្រួលអោយសិក្ខាកាមបែងចែកទៅជាក្រុមតូចៗអាស្រ័យទៅតាមប្រភេទនៃដំណោះស្រាយដែលត្រូវបានបង្ហាញខាងលើ។ អ្នកសម្របសម្រួលពន្យល់កសិករដាំស្រូវពីការបាត់បងប្រាក់ចំនួលទៅតាមសេនារីយ៉ូដែលបានពិភាក្សានៅក្នុងជំហ៊ានទី១ ។
The facilitator then asks participants to form four sub-groups based on the abovementioned four response categories. The facilitator explains the paddy farmers' profit and/or loss in the following scenarios using the figures (in terms of cost) discussed in step 1.

## ជំហ៊ានទី៣ ប្រៀបធៀបប្រាក់ចំនូល ប្រាក់ចំនេញ និងការខាតបងនៃប្រភេទដំណោះស្រាយទាំង៤

**Step 3. Compare incomes, profit and loss of the four groups**

អ្នកសម្របសម្រួលពិភាក្សាលើក្រុមនីមួយៗពីប្រាក់ចំនូលសរុប និងកំហាតបងដែលបណ្តាលមកពីការសម្រេចចិត្តដែលបានមកពីក្រុមនីមួយៗ ហើយបន្ទាប់មកទៀតក្រុមទាំងអស់ត្រូវប្រៀបធៀប និងកំណត់នូវប្រាក់ចំនូល និងការខាតបងយោងទៅតាមសេនារីយ៉ូដូចខាងក្រោម ។
The facilitator discusses with each group the total income and loss resulting from the decisions taken by each group, and together the groups compare and identify which profited and/or lost the most based on the following scenarios.

**សេនារីយ៉ូ១**: ការព្យាករណ៍ត្រឹមត្រូវ

**Scenario 1. The forecast is correct.**

ក្រុមទី ១ ទុកដីទំនេរចោល ក្រុមនេះចំនេញប្រាក់ដែលត្រូវចំណាយក្នុងការដាំដុះ

Group 1. Let the land lie fallow. This group saved the cultivation cost.

ក្រុមទី ២ មិនដាំដុះ ហើយរកការងារផ្សេងធ្វើ ក្រុមនេះចំនេញប្រាក់ដែលត្រូវចំនាយក្នុងការដាំដុះ ហើយអាចរកប្រាក់ចំនូលបន្ថែមពីការងារនោះ

Group 2. Do not plant and temporarily shift to another job or profession. This group saved the cultivation cost and earned from their shift in profession

ក្រុមទី៣ ដូរមុខដំណាំ ក្រុមនេះចំនេញប្រាក់ដែលត្រូវចំណាយក្នុងការដាំដុះហើយអាចរកប្រាក់ចំនូលលបន្ថែមបានពីការដាំដុះដំណាំនោះ

Group 3. Plant other crops. This group saved the cultivation cost and earned from planting other crops.

ក្រុមទី ៤ នៅតែបន្តការដាំដុះ ក្រុមនេះបាត់បងការចំនាយទៅលើការដាំដុះទាំងអស់

Group 4. Keep planting. This group incurred cultivation cost.

**សម្គាល់** ៖ ការចំណាយលើការដាំដុះដែលមិនបាត់បងគឺត្រូវបានចាត់ទុកជាប្រាក់ចំនេញ។ បរិមាណនៃទឹកប្រាក់នោះអាចនិងត្រូវបាត់បងប្រសិនបើកសិករមិនធ្វើតាមការព្យាករណ៍

**Note**: The cultivation cost saved is considered profit. Such amount of money would have been gone, had the farmers not followed the prediction.

**សេនារីយ៉ូ២ ការព្យាករណ៍មិនត្រឹមត្រូវ**

**Scenario 2. The forecast is not correct.**

ក្រុមទី ១ ទុកដីទំនេរចោល ក្រុមនេះបាត់បងឱកាសក្នុងការរកប្រាក់ចំនូល

Group 1. Let the land lie fallow. This group missed the opportunity to earn anything.ក្រុមទី២ មិនដាំដុះតែទៅរកការងារផ្សេងធ្វើ ។ ក្រុមនេះអាចចំនេញឬមិនចំនេញអាស្រ័យទៅលើប្រាក់ចំនូលដែលទទួលបានពីការដាំដុះ និងប្រាកចំនូលពីការងារនោះ

Group 2. Do not plant and temporarily shift to another job or profession. Depending on the potential income from planting versus engaging in another livelihood, this group may be profitable or not.

ក្រុមទី៣ ដាំដំណាំផ្សេង។ ក្រុមនេះអាចចំនេញឬមិនចំនេញអាស្រ័យទៅលើប្រាក់ចំនូលដែលទទួលបានពីការដាំដំណាំនោះ

Group 3. Plant other crops. Depending on the potential income from planting other crops, this group may be profitable or not.

ក្រុមទី៤ នៅតែដាំស្រូវដដែល ក្រុមនេះអាចទទួលបានប្រាក់ចំនូលពីការដាំដុះនេះ

Group 4. Keep planting. This group earned from planting.

**ជំហ៊ានទី៣ ពិភាក្សាពីឧបសគ្គនៃការពឹងផ្អែកទៅលើចំនួល និងកំហាតដែលបានបង្ហាញនៅក្នុងសេនារីយ៉ូខាងលើ**

**Step 4. Discuss the challenges of realizing the profit and loss indicated in the exercise scenarios**

អ្នកសម្របសម្រួលត្រូវតែចង្អុលបង្ហាញថាសេនារីយ៉ូលើចំនួល និងការខាតបង់ជាទូទៅវាអាស្រ័យទៅលើបិរិបទនៃតំបន់នីមួយៗ ដូច្នេះវាងាយស្រួលដល់កសិករក្នុងការកំណត់ឳកាសនៃការរកប្រាក់ចំនូលបន្ថែមទៀតដើម្បីជួយពួកគាត់ក្នុងការកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ចសង្គមធ្ងន់ធ្ងរដល់គ្រួសាររបស់ពួកគាត់។
The facilitator must point out that the profit and loss scenarios generally depend on the local context so that it is critical for farmers to identify other income-earning opportunities available to help them mitigate the socio-economic impacts of extreme events on their families.

## លំហាត់គំរូ
## Sample Exercises

**លំហាត់ទី១** ការព្យាករណ៍នៃភ្លៀងមិនគ្រប់គ្រាន់ កសិករដែលដាំស្រូវរៀបចំដាំដុះសម្រាប់រដូវខាងមុខ។ ពួកគាត់បានទទួលព័ត៌មាននៃការព្យាករណ៍នៃភ្លៀងធ្លាក់ក្រោមកម្រិតធម្មតា និងត្រូវបានណែនាំមិនអោយធ្វើស្រែឡើយ។ នៅក្នុងលំហាត់នេះ សិក្ខាកាមត្រូវបានអោយចែកក្រុមជា ៤ អាស្រ័យទៅលើប្រភេទនៃដំណោះស្រាយដែលបានបង្ហាញនៅក្នុងតារាងខាងក្រោម ។

**Exercise 1. Forecast of Deficit Rainfall**. Paddy farmers are preparing for the upcoming season. They received forecast of below normal rainfall and have been advised not to plant paddy. In this exercise, participants are asked to form four groups based on four categories of responses shown in the following table.

**តារាងទី១០-១ ការព្យាករណ៍ភ្លៀងរយៈពេលមួយរដូវក្រោមកម្រិតធម្មតា ដែលការព្យាការណ៍មានប្រូបាប ៦០%**

Table 10-1. Forecast of below normal seasonal rainfall forecast at 60% probability[13]

| **តួនាទី**<br>Actor | **ការណែនាំ / ការឆ្លើយតប**<br>Advisory/Response | **ផ្សេងៗ**<br>Remarks |
|---|---|---|
| **ការព្យាករណ៍ពីអគ្គនាយកដ្ឋានឧតុនិយម/SESAME**<br>Forecast from DOM/SESAME | ការព្យាការណ៍សម្រាប់ខែ មិថុនា ដល់ សីហា គឺក្រោមកម្រិតធម្មតា<br>- The rainfall forecast for the given period (i.e., June-September) is below normal. | កម្រិតធម្មតាគឺស្ថិតនៅក្នុងចន្លោះ±20% នៃទិន្នន័យអាកាសធាតុជាមធ្យមរយៈពេល៣០ឆ្នាំ<br>- Normal range is within ±20% of the climatological average for the last 30 years |
| **ការណែនាំពីអគ្គនាយកដ្ឋានកសិកម្ម**<br>Advisory from Agriculture Department | ដោយសារតែកង្វះខាតទឹកនៅក្នុងប្រឡាយ ទឹកទឹកមិនគ្រប់គ្រាន់ហើយការស្រោចស្រប គឺពិតជាមានកម្រិត<br>- Due to poor water storage in the Dam, water was not let out and irrigation is very limited | កសិករត្រូវបានណែនាំអោយដាំដំណាំណាដែលមានភាពធនទៅនិងលក្ខខណ្ឌរាំងស្ងួត<br>- Farmers are advised to plant drought-tolerant crops |
| យុទ្ធសាស្ត្រឆ្លើយតបរបស់កសិករ<br>**Farmer Response Strategies** | | |
| **ក្រុមទី១**<br>Group 1 | ធ្វើតាមការណែនាំដោយមិនដាំដំណាំអ្វីទាំងអស់ដោយទុកដីអោយទំនេរចោល<br>- Follows the advisory by not planting and allowing the land to lie fallow | ប្រសិនបើការចំណាយលើការធ្វើស្រែអស់ចំនួន ២១៦ដុល្លា នោះក្រុមនេះអាចសន្សំលុយបាន ២១៦ដុល្លា<br>- IF total cultivation cost is USD216, then this group saves USD216 |

[13] In this exercise, the seasonal forecast was correct.

| តួនាទី<br>Actor | ការណែនាំ / ការឆ្លើយតប<br>Advisory/Response | ផ្សេងៗ<br>Remarks |
|---|---|---|
| | មិនចំណាយប្រាក់ទៅលើការដាំដុះ<br>-Saves the cultivation cost | ប្រាក់សរុបដែលពួកគេទទួលបាននៅចុងបញ្ចប់នៃរដូវគឺ ២១៦ដុល្លា<br>-Total money they have at the end of the season is USD216 |
| **ក្រុមទី ២**<br>Group 2 | -ធ្វើតាមការណែនាំដោយមិនដាំស្រូវ ហើយ ទៅរកការងារផ្សេងវិញ<br>-Follows the advisory by not planting, and temporarily shifting to another job or profession<br>មិនចំណាយប្រាក់ទៅលើការដាំស្រូវ និង រកបានប្រាក់ចំនូលបន្ថែមពីមុខរបរនោះ<br>-Saves the cultivation cost and earns from their temporary job | -ប្រសិនបើក្រុមនេះចិញ្ចឹមសត្វ ដោយចំណាយអស់ ៣៦០ដុល្លា (០.៩ដុល្លាក្នុងមួយក្បាល) និងរកប្រាក់ចំនូលបាន២៨៦ដុល្លាលើប្រាក់ ដែលពួកគាត់គ្រោងនិងចំណាយលើការដាំស្រូវដែលមានចំនួន ២១៦ដុល្លា។<br>-IF the group grew birds, invested USD360 (0.9/bird) and earned USD646 (1.6/bird), then they earned USD286 in addition to their savings of USD 216<br>ប្រាក់សរុបដែលពួកគាត់បន្ទាប់ពីចុងរដូវគឺ ៥០២ដុល្លា<br>-Total money they have at the end of the season is USD502 |
| **ក្រុមទី ៣**<br>Group 3 | -ធ្វើតាមការណែនាំដោយដាំស្រូវដែលធន់និងគ្រោះរាំងស្ងួត<br>-Follows the advisory by planting drought-tolerant crops<br>មិនចំនាយប្រាក់ចំនាយលើការធ្វើស្រែ ហើយ ទទួលបានប្រាក់ចំនូលពីដំណាំដែលបានដាំនោះ<br>-Saves the cultivation cost and earns from other crops | -ប្រសិនបើក្រុមនេះដាំល្ង ដែលចំណាយអ់ស ៧៩ដុល្លាក្នុងមួយហិកតា និងរកប្រាក់ចំនូល បាន២០៨ដុល្លា នោះពួកគាត់បានចំនេញ ចំនួន ២០៨ដុល្លាពីលើលុយដែលពួកគាត់ គ្រោងនិងចំណាយធ្វើស្រែទៀត<br>-IF the group grew gingili, invested USD79/ha and earned USD287/ha, then they earned USD208 in addition to their savings of USD216<br>លុយដែលពួកគាត់នៅសល់នៅចុងរដូវគឺ ៤២៤ដុល្លា<br>-Total money they have at the end of the season is USD424 |
| **ក្រុមទី ៤**<br>Group 4 | -មិនធ្វើតាមការណែនាំ និងនៅតែបន្តដាំ ដំណាំដែលងាយរងគ្រោះដោយគ្រោះរាំងស្ងួត(ឧ. ស្រូវ)<br>-Does not follow the advisory and keeps on planting drought-vulnerable plants (e.g. paddy) | -ប្រសិនបើប្រាក់ចំណាយលើការដាំដុះអស់ ២១៦ដុល្លា នោះប្រាក់ចំនួន ២១៦ ដុល្លានោះនិងខាតបង់<br>-IF total cultivation cost is USD216, then this group lost USD216<br>ប្រាក់សរុបដែលពួកគាត់មាន នៅចុងបញ្ចប់នៃរដូវដាំដុះគឺ -២១៦ ដុល្លា<br>-Total money they have at the end of the season is -USD216 |

**លំហាត់ទី២: ការព្យាករណ៍ដែលបង្ហាញពីភ្លៀងធ្លាក់លើសធម្មតាព្យាករណ៍នៅតាមវគ្គដំណាំផ្សេងៗគ្នា**

កសិករធ្វើស្រូវដែលស្រូវនោះស្ថិតនៅក្នុងវគ្គផ្សេងៗគ្នា។ កសិករទាំងអស់នោះត្រូវបានអោយពិនិត្យមើលលើការព្យាករណ៍រយៈពេល ៧ថ្ងៃ ជាមួយនិងវគ្គដំណាំដែលពួកគាត់មាន និងកំណត់ជម្រើសនៃការឆ្លើយតប។ នៅក្នុងលំហាត់នេះសិក្ខាកាម ចែកកសិករជាបួនក្រុមអាស្រ័យទៅលើវគ្គលូតលាស់ទាំង ៤របស់ស្រូវ ។

**Exercise 2. Forecast of Above Normal Medium-Range Rainfall Forecast at Different Crop Stages**. Paddy farmers are currently at different stages of growing their rice crop. They are asked to correlate the 7-day forecast with their respective crop stage and identify their response options. In this exercise, participants are asked to form four groups based on four different growth stages of paddy.

Table 10-2. Forecast of above normal 7-day rainfall at 80% probability

| **តួនាទី**<br>Actor | **ការណែនាំ / ការឆ្លើយតប**<br>Advisory/Response | **ផ្សេងៗ**<br>Remarks |
|---|---|---|
| ការព្យាករណ៍ពី អគ្គនាយកដ្ឋានឧតុនិយម និងSESAME<br>**Forecast from DOM/SESAME** | -ទឹកភ្លៀងត្រូវបានព្យាករណ៍ (ឧ ៩-១៥ កញ្ញា២០១៩) គឺលើសកម្រិតធម្មតា<br>- The rainfall forecast for the given period (i.e., 9-15 September 2019) is above normal. | កម្រិតធម្មតាគឺស្ថិតនៅក្នុងចន្លោះ ±20% នៃទិន្នន័យអាកាសធាតុជាមធ្យមរយៈពេល៣០ឆ្នាំ<br>- Normal range is within ±20% of the climatological average for the last 30 years |
| **យុទ្ធសាស្ត្រនៃការឆ្លើយតបរបស់កសិករ**<br>**Farmer Response Strategies** | | |
| **ក្រុមទី ១ វគ្គសាបព្រោះឬសំណាប**<br>**Group 1. Sowing /nursery stage** | -វាពិតជាមានសារៈសំខាន់ណាស់ដែលគ្រាប់ស្រូវដែលបានសាបហើយមិនប៉ះពាល់ដោយភ្លៀង ៤៨ម៉ោង ដើម្បីការពារគ្រាប់ស្រូវកុំអោយហូរតាមទឹក<br>- It is critical that sown seeds are not affected by rain up to 48hrs to prevent from drifting/draining of seeds | -ប្រសិនបើប្រាក់ចំនាយទៅលើការសាបគ្រាប់អស់ប្រហែលជា ១១ដុល្លាក្នុង១ហិកតា ដូច្នេះពួកគាត់អាចសន្សំលុយបាន ១១ដុល្លាក្នុង ១ហិកតា ប្រសិនបើពួកគាត់ពន្យាពេលសាបគ្រាប់ដើម្បីជៀសវាងទឹកភ្លៀង<br>-IF total sowing cost is estimated at USD11 per ha, then they saved USD11/ha if they delayed the sowing to avoid the rain |
| **ក្រុមទី ២ វគ្គបង្កបង្កើនផល**<br>**Group 2. Vegetative phase** | - នៅក្នុងលូតលាស់នេះ ជីមានសារៈណាស់ ប៉ុន្តែការដាក់ជីគួរតែគួរតែកំណត់ពេលវេលាដើម្បីជៀសវាងការហូរច្រោះ និងបាត់បង់សារធាតុចិញ្ចឹងដោយសារភ្លៀងខ្លាំង<br>- During this phase, fertilizers are crucial, but application should be “timed” to avoid potential erosion and nutrient loss due to heavy rainfall | - ប្រសិនបើថ្លៃចំណាយលើជីសរុបអស់ប្រហែលជា ៩ដុល្លាក្នុងមួយហិកតា នោះពួកគាត់សន្សំបានប្រាក់ ៩ដុល្លាក្នុងមួយហិកតា ប្រសិនបើពួកគាត់ពន្យាពេលដាក់ជីដើម្បីជៀសវាងភ្លៀងធ្លាក់<br>- IF total fertilizer cost is estimated at USD9 per ha, then they saved USD9/ha if they delayed fertilizer application to avoid the rain |
| **ក្រុមទី ៣ វគ្គបង្កបង្កើនផល**<br>**Group 3. Reproductive phase** | -ការដាក់ជីអ៊ុយរ៉េបំប៉ន់គឺមានសារៈសំខាន់ណាស់នៅក្នុងវគ្គនេះ ប៉ុន្តែការដាក់ជីគួរតែ ពន្យាពេលព្រោះថាការព្យាករណ៍បង្ហាញថាភ្លៀងធ្លាក់ខ្លាំង<br>- Top dressing of urea fertilizer is important at this stage, but may need to be postponed due to the forecasted heavy rainfall<br>-វាពិតជាមានសារៈសំខាន់ណាស់ដែលមាន ពន្លឺព្រះអាទិត្យគ្រប់គ្រាន់២៥ថ្ងៃមុនពេ | -ប្រសិនបើការចំណាយប្រាក់សរុបអស់ ៩ដុល្លាក្នុងមួយហិកតា នោះពួកគាត់សន្សំបាន៩ដុល្លាក្នុងមួយហិកតាប្រសិនបើពួកគាត់ពន្យាពេលនៃការដាក់ជីដើម្បីជៀសវាងភ្លៀង<br>- IF total fertilizer cost is estimated at USD9 per ha, then they saved USD9/ha if they delayed fertilizer application to avoid the rain<br>-ការកើនឡើងទិន្នផលប្រជាពិបាកក្នុងការប៉ាន់ស្មាន |

| តួនាទី<br>Actor | ការណែនាំ / ការឆ្លើយតប<br>Advisory/Response | ផ្សេងៗ<br>Remarks |
|---|---|---|
| | ល<br>ចេញផ្កាដើម្បីការវិវឌ្ឍន៍នៃប្រដាប់បន្តពូជរបស់ស្រូវ និងគួរស្រូវផងដែរ<br>- It is crucial to have good solar radiation 25 days before flowering for development of floral parts and spikelets<br>-ភ្លៀងធ្លាក់ខ្លាំងបង្កើនកម្រិតទឹកនៅក្នុងវាលស្រែ និងបន្ថយសីតុណ្ហភាពដែលធ្វើអោយបាត់បង់សារធាតុចិញ្ចឹមតូចៗដូចជាស័ង្កសី និង ទង់ដែង<br>- Heavy rainfall increases the water in the field and decreases the temperature leading to potential unavailability of micronutrients like Z and Cu.<br>-ទឹកគួរតែបង្ហូរចេញអោយបានឆាប់ដើម្បី បង្កើនសីតុណ្ហភាពដីនិងទប់សារធាតុចិញ្ចឹមនិងបង្កើនទិន្នផលស្រូវ<br>- Water should be drained immediately to increase soil temperature and availability of micronutrients, and ultimately the harvest index | - Slight increase in harvest index may be difficult to estimate |
| **ក្រុមទី ៤ វគ្គទុំ និងប្រមូលផល**<br>**Group 4. Ripening and harvesting stage** | -ភ្លៀងធ្លាក់ដែលបានរំពឹងទុកប្រហែលជាធ្វើអោយទឹកជំ ដែលម៉ាស៊ីនច្រូតមិនអាចដំណើរការល្អ<br>- Expected heavy rain may lead to waterlogging, where machines are unable to function efficiently<br>-ការប្រមូលផលអាចធ្វើទៅអោយបានមុនដើម្បីជៀសវាងការចំណាយលើពលកម្មក្នុងការប្រមូលផល<br>- Harvest could be done in advance to avoid manual labor costs of harvesting | -ប្រសិនបើថ្លៃចំណាយពលកម្មនៃការប្រមូលផលអស់ ១៣៥ហិកតា ហើយខាតពីការប្រមូលផលលើកមុន ៥៨ដុល្លា នោះក្រុមនេះនិងសន្សំបានប្រាក់ ៧៧ដុល្លា<br>- IF manual labor cost of harvesting is USD135/ha and loss from early harvest is USD58, then the group saved USD77 (135-58) |

**លំហាត់ទី ៣** ការព្យាករណ៍ថាភ្លៀងធ្លាក់លើសកម្រិតធម្មតា ។ កសិករធ្វើស្រែគឺបានបោះបង់ការធ្វើស្រែដោយទុកដីអោយទំនេរចោល ហើយកសិករគិតដល់ការព្យាករណ៍រយៈពេល៧ថ្ងៃស្របតាមស្ថានភាពរបស់ពួកគេ និងកំណត់ជម្រើសនៃការឆ្លើយតបរបស់ពួកគេ។ នៅក្នុងលំហាត់នេះ សិក្ខាកាមត្រូវបែកចែកក្រុមជាបួនយោងទៅតាមសេណារីយ៉ូផ្សេងៗគ្នា

**Exercise 3. Forecast of Above Normal Rainfall**. Paddy fields are current fallow, and farmers are asked to correlate the 7-day forecast with their respective situation and identify their response options. In this exercise, participants are asked to form four groups based on four different scenarios.

**Table 10-3. Forecast of above normal 7-day rainfall at 80% probability**

| តួនាទី<br>Actor | ការណែនាំ / ការឆ្លើយតប<br>Advisory/Response | ផ្សេងៗ<br>Remarks |
|---|---|---|
| ការព្យាករណ៍ពីអគ្គនាយកដ្ឋានឧតុនិយម និងSESAME<br>**Forecast from DOM/SESAME** | - ភ្លៀងធ្លាក់ដែលបានព្យាករណ៍គឺ (ឧ. ៩-១៥ កញ្ញា ២០១៩) លើសកម្រិតធម្មតា<br>- The rainfall forecast for the given period (i.e., 9-15 September 2019) is above normal. | កម្រិតធម្មតាគឺស្ថិតនៅក្នុងចន្លោះ ±20% នៃទិន្នន័យអាកាសធាតុជាមធ្យមរយៈពេល៣០ឆ្នាំ<br>- Normal range is within ±20% of the climatological average for the last 30 years |
| យុទ្ធសាស្ត្រនៃការឆ្លើយតបរបស់កសិករ<br>**Farmer Response Strategies** | | |
| **ក្រុមទី១ ទុកដីអោយទំនេរចោលបន្ទាប់ពីភ្ជួរហើយបានម្តងឬ២ដង**<br>Group 1. Fallow with 1 or 2 dry ploughing | - ដីប្រហែលជាអាចព្រោះគ្រាប់បាន ប៉ុន្តែប្រហែលជាមិនល្អទេក្នុងការភ្ជួររាស់ដោយសារតែភ្លៀងធ្លាក់ខ្លាំងនៅថ្ងៃខាងមុខ<br>- Fields are ready to take up direct sowing of paddy, but it may be unproductive to till the soil due to upcoming heavy rainfall | - IF total sowing cost is estimated at USD11 per ha, then they saved USD11/ha if they delayed the sowing to avoid the rain |
| **ក្រុមទី ២ ទុកដីអោយទំនេរចោលដោយមិនបានភ្ជួរ**<br>Group 2. Fallow fields without any ploughing | - ព្រោះតែដីជាប្រភេទដីឥដ្ឋ ការភ្ជួររាស់គឺពិតជាពិបាកដោយសារតែការព្យាការណ៍បានបង្ហាញថាភ្លៀងនិងធ្លាក់ខ្លាំង<br>- As the soil is heavy clay, ploughing is difficult given the forecasted heavy rains | - ប្រសិនបើការភ្ជួរដីចំណាយប្រហែលជា ១៤ដុល្លាក្នុងមួយហិកតាហើយក្រុមនេះសម្រេចភ្ជួរដីតែម្តងហើយព្រោះគ្រាប់យកតែម្តងពួកគាត់អាចសន្សំប្រាក់ប្រដែលជា ១៤ដុល្លាក្នុង១ហិកតា<br>- IF total ploughing cost is USD14/ha and the group decide to only plough once followed by direct seeding after the rain, they are able to save USD14/ha |
| **ក្រុមទី៣ ស្រែទើបតែព្រោះកូនរួច**<br>Group 3. Fields recently sown direct | - ភ្លៀងធ្លាក់ខ្លាំងប្រដែលជាធ្វើអោយគ្រាប់ដែលបានព្រោះរួចនោះកប់ក្នុងដីជ្រៅ ឬហូរទៅកន្លែងដែលដីដែលទាប ដែលវាកាត់បន្ថយចំនួនគ្រាប់ដែលបណ្តាលអោយមានដើមដុះមិនស្មើរគ្នា<br>- Heavy rainfall may cause sown seeds to go deep into the soil or drift/drain to the lower end of the field, reducing their population and causing uniformity in stand | - ប្រសិនបើថ្លៃចំណាយក្នុងការព្រោះគ្រាប់លើកទី២អស់ ៤ដុល្លាក្នុងមួយហិកតា ថ្លៃបង្ហូរទឹកចេញអស់ ២ដុល្លាក្នុងមួយហិកតា ហើយក្រុមនេះសម្រេចចិត្តបង្ហូរទឹកចេញជំនួសអោយការព្រោះលើកទី២ ដូច្នេះពួកគាត់អាចសន្សំបានប្រាក់ ២ដុល្លាក្នុងមួយ ហិកតា<br>- IF cost of second sowing is USD4/ha, cost of draining is USD2/ha, and the group decides to drain instead of 2nd sow, then they are able to save USD2/ha |
| **ក្រុមទី ៤ កូនដំណុះស្រូវបានរយៈពេល១សប្តាហ៍**<br>Group 4. Week-old directly sown | - ភ្លៀងប្រហែលជាធ្វើអោយទឹកដក់ និងបំផ្លាញកូនសំណាប់តូចៗដែលធ្វើអោយថយចំនួនដើមនិងទិន្នផល<br>- Rain may cause waterlogging and damage the young seedlings thereby reducing their population and potential yield | - ប្រាក់ចំនូលថយចុះអាចប៉ាន់ប្រមាណបានតែនៅពេលប្រមូលផល<br>- Income loss can be assessed only on harvest |

មេរៀនទី ១១  ការចុះទៅក្នុងស្រែចំការ

## 11. Module Eleven: Farm Visit

កម្មវិធី FARM Schoolអាចត្រូវបានប្រើប្រាស់ដើម្បីភ្ជាប់ព័ត៌មានអាកាសធាតុ និងធាតុអាកាសទៅដល់កសិករដែលជាអ្នកប្រើប្រាស់ចុងក្រោយ។ វាក៏អាចត្រូវបានប្រើប្រាស់ជាកន្លែងផ្សព្វផ្សាយពីរបៀបប្រើប្រាស់ព័ត៌មានក្នុងការរួមបញ្ចូលការរៀបចំផែនការ និងការសម្រេចចិត្តក្នុងការងារកសិកម្មផងដែរ ហើយណាមួយទៀតវាអាចជួយអោយកសិករ អនុវត្តន៍វិធីសាស្ត្រគ្រប់គ្រងសមរម្យដើម្បីកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរនៃអាកាសធាតុ។ ក្នុងហេតុផលនេះវាពិតេជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការចុះទៅស្រែចំការផ្ទាល់ដើម្បីពង្រឹងមេរៀនដែលបានបង្រៀន និងដើម្បីបង្ហាញទៅកសិករដទៃទៀត ក៏ដូចជាសហគន៍ដទៃទៀតផងពីគុណប្រយោជន៍នៃកម្មវិធី ។ ស្រដៀងគ្នានិងនេះដែរការវាយតម្លៃគឺរិតតែសំខាន់ដើម្បីដឹងពីអ្នកសម្រប់សម្រួល មាតិកា និងដំណើរការក៏ដូចជាការបង្រៀនមេរៀនដើម្បីជាទុនមួយក្នុងការធ្វើអោយកម្មវិធីនេះរិតតែល្អប្រសើរឡើង ។

The FARM School program can be used to communicate weather and climate information to end-users (i.e., farmers). It can also be used as a venue for demonstrating how information can be integrated in farm-level planning and decision-making, where farmers take appropriate measures to mitigate the impact of extreme climate events. For this reason, it is essential to conduct a Farm Visit to reinforce the concepts taught, and to demonstrate to other farmers and the community the benefits of the program. Similarly, the evaluation is critical to assess the facilitators, the content, process as well as delivery of the program so that it can be improved.

### 11.1 Farm Visit

តាមមេរៀន និងផ្នែកនីមួយៗរបស់មេរៀន អ្នកសម្របសម្រួលចាប់ផ្តើមចុះទៅវាលស្រែដោយមានការពិភាក្សាទៅលើយុទ្ធសាស្រ្តនៃការដាំដុះ និងតុល្យភាពទឹកនៅក្នុងដីជាមួយនិងអ្នកចូលរួម ។ បន្ទាប់មកទៀតពិភាក្សាពីការដាក់ជី ក៏ដូចជារោគសញ្ញារបស់សមាសធាតុចង្រៃ និងជម្ងឺដែលមាននៅក្នុងទីវាល។

Following the module/session outline, the facilitator starts the farm visit with a brief discussion on cropping strategies and soil water balance with all participants. They then discuss fertilizer as well as pest and disease symptoms found in the field.

#### ១១.១.១ គោលបំណង

#### 11.1.1 Objectives

បន្ទាប់ពីបញ្ចប់មេរៀននេះសិក្ខាកាមគួរតែអាច

At the end of the session, participants should be able to:

បង្ហាញការយល់ដឹងអំពីយុទ្ធសាស្រ្តនៃការដាំដុះ និង តុល្យភាពទឹកនិងដី

- Show understanding of cropping strategies and field water balance

ពិភាក្សាទៅលើសញ្ញាណនៃកង្វះខាតនៃសារធាតុចិញ្ចឹមដែលមាននៅក្នុងវាល

- Discuss common nutrient deficiencies and pest and disease symptoms found in the farm

ចែករំលែកបទពិសោធន៍របស់ពួកគាត់ទៅលើកម្មវិធី FARM School ទៅដល់កសិករផ្សេងៗទៀត

- Share their experience of the FARM School program to other farmers

### ១១.១.១ ពេលវេលា
### 11.1.2 Session Time
មេរៀននេះមានពេលប្រហែល ២ម៉ោង
This session takes about 2 hours.

### 11.1.3 Materials Needed
កាមេរ៉ា
Camera
រូបភាពនៃសញ្ញាណនៃកង្វះសារធាតុចិញ្ចឹម
Photos of nutrient deficiency symptoms for macro-nutrients
រូបភាពសត្វល្អិតចង្រៃ និងជម្ងឺ
Photos of pests and diseases

### ១១.១.១ ពេលវេលា
### 11.1.4 Guide

#### ជំហ៊ានទី ១ ពិភាក្សាលើយុទ្ធសាស្ត្រដាំដុះ និងតុល្យភាពទឹកនៅក្នុងដី
**Step 1. Discuss cropping strategies and field water balance**

អ្នកសម្របសម្រួលសួរសិក្ខាកាមអំពីវដ្តដំណាំនិងប្រតិទិន្នដាំដុះ ប្រភេទដី និងប្រភពទឹកសម្រប់ផ្គត់ផ្គងដំណាំ។ សកម្មភាពនេះត្រូវបានធ្វើឡើងបន្ទាប់ពីការពិភាក្សាទៅលើទឹកភ្លៀងនៅក្នុងតំបន់ក៏ដូចជាត្រូវការទឹករបស់ដំណាំផងដែរ។
The facilitator asks participants about the cropping cycle and calendar, the type of soil, and sources of water for the crops. This is followed by a discussion of the rainfall pattern in the area vis-à-vis the crop water requirements.

#### ជំហ៊ានទី ២ កំណត់អត្តសញ្ញាណនៃកង្វះសារធាតុចិញ្ចឹម សត្វល្អិត និងជម្ងឺ
**Step 2. Identify nutrient deficiencies, and pest and disease symptoms**
អ្នកសម្របសម្រួលអោយសិក្ខាកាមអង្កេតមើលដំណាំ (ឧ. ដើម ស្លឹក ផ្កា និងផ្លែ) និងកំណត់អត្តសញ្ញាណ និងរោគសញ្ញានៃកង្វះសារធាតុចិញ្ចឹម ការបំផ្លាញរបស់សត្វល្អិត និងជម្ងឺ។ បន្ទាប់មកទៀតសិក្ខាកាមកំណត់ប្រភេទសារធាតុចិញ្ចឹមដែលមិនមាន និងជីដែលត្រូវការ ។ សិក្ខាកាមក៏ត្រូវអង្កេតសត្វល្អិតចង្រៃ និងជម្ងឺ និងកំណត់យុទ្ធសាស្ត្រគ្រប់គ្រងបញ្ហាទាំងអស់នោះ។
The facilitator asks participants to observe the crops (e.g., stem, leaf, flower, fruit) and identify signs and symptoms of nutrient deficiency, pest and/or disease incidence. After which, they identify the type of nutrient missing and the required fertilizer. They also identify the pest and/or disease and identify the management strategy for addressing the problem/s.

#### ជំហ៊ានទី ៣ ការចែករំលែកបទពិសោធន៍ និងការយល់ដឹងពីកម្មវិធី FARM School
**Step 3. Sharing of experiences and insights from the FARM School program**
អ្នកសម្រប់សម្រួលអោយសិក្ខាកាមចែករំលែកដោយសង្ខេបពីបទពិសោធន៍ និងការយល់ដឹងរបស់ពួកគេពីកម្មវិធី FARM School ។ បទពិសោធន៍និងការយល់ដឹងនេះអាចចែករំលែកបន្តទៅដល់កសិករដទៃទៀតក៏ដូចជាសហគមន៍ផងដែរ។
The facilitator asks participants to briefly share their experience and insights from the program. This experience and insight sharing may be conducted in the presence of other farmers and the wider community.

# កម្រងសំនួរស្ទង់មតិ

## Appendix A. Assessment Survey Questionnaire

| | | |
|---|---|---|
| ឈ្មោះកសិករ | Farmer's Name | : ________________________________________ |
| អាយុ | Age | : ________________________________________ |
| ឈ្មោះក្រុមកសិករ | Farmers' Group Name | : ________________________________________ |
| ឃុំ | Commune | : ________________________________________ |
| ស្រុក | District | : ________________________________________ |
| ខេត្ត | Province | : ________________________________________ |
| ថ្ងៃបរិច្ឆេត | Date of Survey | : ________________________________________ |

| **Background Information**<br>ពត៌មានទូទៅ | | | | | |
|---|---|---|---|---|---|
| Farm Size (Please tick):<br>ទំហំដី (សូមគូសគ្រីស) | Less than 2,500 sqm<br>តិចជាង ២៥០០ ម៉ែត្រការ៉េ | 2,501-5,000 sqm<br>២៥០១-៥០០០ ម៉ែត្រការ៉េ | 5,001-7,500 sqm<br>៥០០១-៧៥០០ ម៉ែត្រការ៉េ | 7,501-10,000 sqm<br>៧៥០១-១០០០០ ម៉ែត្រការ៉េ | More than 10,000 sqm<br>ច្រើនជាង១០០០០ ម៉ែត្រការ៉េ |
| Landholding (Please tick):<br>កម្មសិទ្ធដី | Owner<br>ជាម្ចាស់ | Tenant<br>ជួល | Sharecropping<br>ម្ចាស់ដីជួល | Others (please specify):<br>ផ្សេងៗ | |
| Irrigation Type (Please provide area per type):<br>ប្រភេទនៃការស្រោចស្រប | Rained:<br>ពឹងផ្អែកទឹកភ្លៀង | Semi-permanent irrigation:<br>មានទឹកខ្លះសម្រាប់ការស្រោចស្រប | | Permanent irrigation:<br>មានទឹកសម្រាប់ការស្រោចស្របរហូត | |
| Income per Year (Please provide amount per type):<br>ប្រាក់ចំនូលក្នុង១ឆ្នាំ (សូមប្រាប់ប្រាក់ចំនូលតាមប្រភេទនីមួយៗ) | Paddy:<br>ស្រូវ | Perennial Crops:<br>ដំណាំមានអាយុកាលវែង | Animals:<br>ចញ្ចឹមសត្វ | Fisheries:<br>ចញ្ចឹមត្រី | Salt Production:<br>ផលិតកម្មអំបិល |
| | Cash Crops:<br>ដំណាំឧស្សាហកម្ម | Forestry:<br>ព្រៃឈើ | Other income sources (please specify):<br>ប្រភពផ្សេងៗទៀត ៖ | | |
| Farm System (Please provide area per type):<br>ប្រព័ន្ធដាំដុះ (សូមប្រាប់ពីផ្ទៃដីតាមប្រភេទនីមួយៗ) | Paddy rice with permanent irrigation:<br>ដាំស្រូវដោយបញ្ចូលទឹករហូត | Rained:<br>ពឹងទឹកភ្លៀង | Mixed Crops:<br>ដំណាំចម្រុះ | Rice-Fish Culture:<br>ដាំស្រូវដោយចិញ្ចឹមត្រីនៅក្នុងស្រែ | Others<br>ផ្សេងៗទៀត |

| | | | | | |
|---|---|---|---|---|---|
| | | | | | |

| Rice crop per year for the last 10 years<br>**ការដាំដុះស្រូវក្នុង១ឆ្នាំសម្រាប់រយៈពេល ១០ឆ្នាំ** | Cycle 1<br>Planting/Harvesting Dates<br>វដ្តទី ១<br>ថ្ងៃបរិច្ឆេទដាំដុះនិងប្រមូលផល | Cycle 2<br>Planting/Harvesting Dates<br>វដ្តទី ១<br>ថ្ងៃបរិច្ឆេទដាំដុះនិងប្រមូលផល | Cycle 3<br>Planting/Harvesting Dates<br>វដ្តទី ១<br>ថ្ងៃបរិច្ឆេទដាំដុះនិងប្រមូលផល |
|---|---|---|---|
| 1. 2010 | | | |
| 2. 2011 | 1. | 1. | 1. |
| 3. 2012 | 2. | 2. | 2. |
| 4. 2013 | 3. | 3. | 3. |
| 5. 2014 | 4. | 4. | 4. |
| 6. 2015 | 5. | 5. | 5. |
| 7. 2016 | 6. | 6. | 6. |
| 8. 2017 | 7. | 7. | 7. |
| 9. 2018 | 8. | 8. | 8. |
| 10. 2019 | 9. | 9. | 9. |
| | 10. | 10. | 10. |

| Cash Crops (Please list):<br>ដំណាំឧស្សាហកម្ម(សូមសរសេរចូល) | Planting Date/s<br>ថ្ងៃបរិច្ឆេទដាំដុះ | Harvest Date/s<br>ថ្ងៃប្រមូលផល |
|---|---|---|
| 1.<br>2.<br>3.<br>4.<br>5. | 1.<br>2.<br>3.<br>4.<br>5. | 1.<br>2.<br>3.<br>4.<br>5. |

| Perennials (Please list):<br>ដំណាំរយៈពេលវែង(សូមសរសេរចូល) | ថ្ងៃប្រមូលផល |
|---|---|
| 1.<br>2.<br>3.<br>4.<br>5. | 1.<br>2.<br>3.<br>4.<br>5. |
| Income per year (Please indicate amount):<br>ប្រាក់ចំនូលប្រចាំឆ្នាំ | |

**Weather/Climate-related Information**

| ព័ត៌មានទាក់ទងទៅនិងធាតុអាកាសនិងអាកាសធាតុ | | |
|---|---|---|
| Rainy Season<br>រដូវវស្សា<br>Dry Season<br>រដូវប្រាំង | Onset (Month and week #)<br>ពេលវេលាដែលចាប់ផ្តើម | Withdrawal (Month and week #)<br>ពេលវេលាដែលចាប់ផ្តើម |
| Negative impact caused by weather/climate-related hazards on the farm<br>ផលប៉ះពាល់អវិជ្ជមានដោយធាតុអាកាស<br>និងអាកាសធាតុទៅលើការដាំដុះ<br>1. Gust wind ល្បឿនខ្យល់<br>2. Flood ទឹកជំនន់<br>3. Drought គ្រោះរាំងស្ងួត<br>4. Heavy rainfall ភ្លៀងធ្លាក់ខ្លាំង<br>5. Others ផ្សេងៗ | Crop Stage<br>ដំណាក់កាលលូតលាស់<br>1.<br>2.<br>3.<br>4.<br>5. | Please indicate frequency of impact with a = never, b = rarely, c = often and d = always[14]<br>សូមបង្ហាញពីភាពញឹកញាប់នៃបញ្ហាទាំងអស់នោះ<br>a មិនដែល b កម្រ c ជារឿយៗ d ជានិច្ចកាល<br>1.<br>2.<br>3.<br>4.<br>5. |

| **Use of Traditional Forecast**<br>**ការប្រើប្រាស់ការព្យាករណ៍បុរាណ** | |
|---|---|
| Traditional forecast used<br>ការព្យាករណ៍បុរាណមាន<br>1.ពពក Clouds, etc<br>2. ដើមឈើដំណាង Indicator trees<br>3. សត្វដំណាងIndicator animals/insects<br>4. Others (please specify) | Please rate your frequency of use with a = never, b = rarely, c = often and d = always.<br>សូមបង្ហាញពីភាពញឹកញាប់នៃបញ្ហាទាំងអស់នោះ<br>a មិនដែល b កម្រ c ជារឿយៗ d ជានិច្ចកាល<br>1.<br>2.<br>3.<br>4. |
| ប្រភពនៃការព្យាករណ៍បុរាណ<br>Source of traditional forecast<br>1. Oldest man/woman<br>ចាស់ៗ<br>2. Commune Leader<br>មេឃុំ<br>3. Others (please specify)<br>ផ្សេងៗ | Please rate the frequency of release of traditional forecast with a = never, b = rarely, c = often and d = always.<br>សូមបង្ហាញពីភាពញឹកញាប់នៃបញ្ហាទាំងអស់នោះ<br>a មិនដែល b កម្រ c ជារឿយៗ d ជានិច្ចកាល<br>1.<br>2. |

[14] Rarely means 2-3 times, often is 5-6 times, and always is more than 8 times during the last 10 years.
កម្រមានន័យថាកើតឡើង ២ទៅ ៣ដងក្នុងរយៈពេល ៨ឆ្នាំ ជារឿយៗមានន័យថា ៥ទៅ៦ដងក្នុងរយៈពេល ៨ឆ្នាំ និង ជាញឹកញាប់មានន័យថា ៨ដងក្នុងរយៈពេល ៨ឆ្នាំ

<table>
<tr><td></td><td colspan="5">3.</td></tr>
<tr><td>Farmers in the commune using traditional forecast (please tick):<br>កសិករនៅក្នុងឃុំប្រើប្រាស់ពត៌មាននៃការព្យាការណ៍បុរាណនេះ (សូមគ្រីស)</td><td>Nobody<br>គ្មាននរណាប្រើ</td><td>10-25% of the time<br>ប្រើប្រហែល<br>10-25%</td><td>26-50% of the time<br>ប្រើប្រហែល<br>26-50%</td><td>51-75% of the time<br>ប្រើប្រហែល<br>51-75%</td><td>More than 75% of the time<br>ប្រើច្រើនជាង 75%</td></tr>
<tr><td>Level of success/accuracy of traditional forecasts (please tick)<br>កម្រិតនៃភាពជោគជ័យឬត្រឹមត្រូវនៃការព្យាករណ៍បែបបុរាណនេះ (សូមគ្រីស)</td><td>0% / Failure<br>គ្មានខុសទេ</td><td>10-25% of the time<br>ខុស10-25%</td><td>26-50% of the time<br>ខុស26-50%</td><td>51-75% of the time<br>ខុស51-75%</td><td>More than 75% of the time<br>ខុសច្រើនជាង 75%</td></tr>
<tr><td colspan="6">Current Use Forecasts<br>ការព្យាករណ៍បច្ចុប្បន្ន</td></tr>
<tr><td>Forecast information currently used<br>ពត៌មានការព្យាករណ៍បច្ចុប្បន្នមាន<br>1.រាល់ថ្ងៃ Daily<br><br>2.៧ថ្ងៃ 7-day<br><br>3. ប្រចាំខែ Monthly<br><br>4. ប្រចាំរដូវ Seasonal<br><br>5.ផ្សេងៗ Others</td><td colspan="5">សូមបង្ហាញពីភាពញឹកញាប់នៃបញ្ហាទាំងអស់នោះ<br>a មិនដែល b កម្រ c ជារឿយៗ d ជានិច្ចកាល<br>ប្រសិនបើមិនប្រើព័ត៌មានសូមពន្យល់ហេតុផល<br>Please indicate frequency of use with a = never, b = rarely, c = often and d = always. If not using the information, please explain why.<br><br>1.<br><br>2.<br><br>3.<br><br>4.<br><br>5.</td></tr>
<tr><td>Dissemination channel used to access information<br>បណ្តាញផ្សព្វផ្សាយ ព័ត៌មាន<br>1. វិទ្យុRadio<br><br>2. ទូរទស្សន៍TV<br><br>3. កាសែតNewspaper<br><br>4. ការប្រជុំឃុំ Commune meetings<br><br>5.វេបសាយរបស់ DOM Website<br><br>6. បណ្តាញសង្គម Social Media (e.g., Telegram, FB, etc)<br><br>7. កម្មវិធីទូរស័ព្ទ Mobile application<br><br>8. ផ្សេងៗ Others (please specify)</td><td colspan="5">សូមបង្ហាញពីភាពញឹកញាប់នៃបញ្ហាទាំងអស់នោះ<br>a មិនដែល b កម្រ c ជារឿយៗ d ជានិច្ចកាល<br>Please rate the frequency of using the dissemination channel with a = never, b = rarely, c = often and d = always.<br><br>1.<br><br>2.<br><br>3.<br><br>4.<br><br>5.<br><br>6.<br><br>7.<br><br>8.</td></tr>
<tr><td>View of risks associated with probabilistic forecast<br>ទស្សនៈអំពីហានិភ័យជាមួយនិងប្រូបាបនៃការព្យាករណ៍</td><td colspan="2">Acceptable<br>ទទួលយកបាន</td><td colspan="2">Not acceptable<br>ទទួលយកមិនបាន</td><td>Comments:<br>មិតិយោបល់</td></tr>
<tr><td colspan="6">Forecast Information Needs and Requirements</td></tr>
</table>

| តម្រូវការនៃព័ត៌មានព្យាករណ៍ | | | | | |
|---|---|---|---|---|---|
| **Rainy season**<br>**រដូវភ្លៀង**<br><br>1. Seeding<br>ដំណុះគ្រាប់<br><br>2. Transplanting<br>ស្ទូង<br><br>3. Tillering<br>បែកគុម្ព<br><br>4. Flowering<br>ផ្កា<br><br>5. Harvesting<br>ប្រមូលផល<br><br>**Dry season**<br>**រដូវប្រាំង**<br><br>1. Seeding<br>ដំណុះគ្រាប់<br><br>2. Transplanting<br>ស្ទូង<br><br>3. Tillering<br>បែកគុម្ព<br><br>4. Flowering<br>ផ្កា<br><br>5. Harvesting<br>ប្រមូលផល | Forecast information needed, and lead-time required at each stage<br>ព័ត៌មាននៃការព្យាករណ៍អាកាសធាតុដែលចាំបាច់ និងពេលវេលាដែលវគ្គលូតលាស់នីមួយៗត្រូវការ<br>1.<br><br>2.<br><br>3.<br><br>4.<br><br>5.<br><br>1.<br><br>2.<br><br>3.<br><br>4.<br><br>5. | | | | |
| Minimum forecast accuracy willing to tolerate (please tick):<br>ការព្យាករណ៍ដែលមានភាពត្រឹមត្រូវកម្រិតមធ្យមដែលអាចទទួលយកបាន | 50% | 60% | 70% | 80% | **ច្រើនជាង**<br>More than 90% |

## ឧបសម្ព័ន្ធ B ស្ថានភាពអាកាសធាតុនៅក្នុងខេត្តបាត់ដំបង

## Appendix B. Climate Profile and Projections for Battambang Province

### ទ្រង់ទ្រាយនៃទឹកភ្លៀង
### 1. Rainfall Pattern

រដូវភ្លៀងនៅក្នុងខេត្តបាត់ដំបងចាប់ផ្តើមពីខែ ឧសភា ដល់ ខែតុលា ។ ទឹកភ្លៀងកម្រិតខ្ពស់កើតឡើងនៅចុងរដូវវស្សាគឺនៅក្នុងកំឡុងខែតុលា ដែលចាប់ពីខែសីហាដល់ខែតុលាគឺជាពេលដែលសើមខ្លាំង។ ទឹកភ្លៀងប្រចាំឆ្នាំជាមធ្យមនៅក្នុងខេត្តបាត់ដំបងគឺមានកម្ពស់ ១៣០០ មីលីម៉ែត្រ ។ ក្រាហ្វិក ទី ១បង្ហាញពីភ្លៀងធ្លាក់ជាមធ្យមប្រចាំខែ។

The rainy season in Battambang occurs from May to October. Highest rainfall is likely to occur and the end of the rainy season, in October, in which August to October is defined as the wettest months. The annual average rainfall of Battambang is 1300 mm. Figure 1 indicates the average monthly rainfall.




**ក្រាហ្វិក១ ភ្លៀងធ្លាក់ប្រចាំខែជាមធ្យមនៅក្នុងខេត្តបាត់ដំបងតាមទិន្នន័យចាប់ពីឆ្នាំ ១៩៨១ ដល់ ២០១៧**

**Figure B-1. Monthly average rainfall over Battambang, 1981-2017**

ការប្រែប្រួលនៃចន្លោះពេលប្រចាំឆ្នាំត្រូវបានបង្ហាញនៅក្នុងការវិភាគរយៈពេល ៣៧ឆ្នាំ (១៩៨១-២០១៧) នៅក្នុងខេត្តបាត់ដំបង។ វាបានបង្ហាញថា កម្រិតភ្លៀងធ្លាក់ធម្មតា(±20% នៃកម្រិតមធ្យម) ក្នុងរយៈពេល ៣០ឆ្នាំ ជាមួយនិងកម្រិតភ្លៀងធ្លាក់លើសកម្រិតធម្មតារយៈពេល ៣ឆ្នាំ និងរយៈពេល៤ឆ្នាំទៀតដែលត្រូវបានសង្កេតឃើញថាមានភ្លៀងធ្លាក់ក្រោមកម្រិតធម្មតា ។

Inter-annual variability could be observed in Battambang in the 37 years of analysis (1981-2017). Accordingly, there were thirty (30) years with normal rainfall (±20% of average), along with three (3) years where above normal rainfall was observed and four (4) years were seen to have received below normal rainfall.

កម្រិតភ្លៀងធ្លាក់ខ្ពស់បំផុតត្រូវបានកើតឡើងនៅក្នុងឆ្នាំ ២០១១ ដែលមានកម្ពស់១៧០៧ មីលីម៉ែត្រ ស្របពេលឆ្នាំដែលមានភ្លៀងធ្លាក់តិចនៅឆ្នាំ ២០១៤ ដែលកម្រិតទឹកភ្លៀងមានត្រឹមតែ ៨៧៨ មីលីម៉ែត្រប៉ុនោះ។

The highest rainfall was observed in 2011, with 1707 mm. The driest year in the considered period was 2014 having received only 878 mm of rainfall.

## ២. ភ្លៀងនៅក្នុងរដូវប្រាំង និង រដូវវស្សា

## 2. Wet and Dry Season Rainfall

៨៣% នៃភ្លៀងធ្លាក់ប្រចាំឆ្នាំនៅក្នុងខេត្តបាត់ដំបងគឺកើតឡើងក្នុងរដូវវស្សា ។ ប៉ុន្តែកម្រិតភ្លៀងធ្លាក់ខុសៗគ្នាត្រូវបានកើតឡើងក្នុងឆ្នាំ ១៩៨១, ១៩៩៩, ២០០២, ២០០៨ និង ២០១៧ ខណៈពេលដែលភ្លៀងនៅក្នុងរដូវប្រាំងត្រូវបានសង្កេតឃើញថាមានច្រើនជាងលើលលុបពីកម្រិតធម្មតា ២២៥ មល។ តារាងទី២ បង្ហាញពីបប្រែបប្រួលនៃភ្លៀងធ្លាក់នៅក្នុងរដូវប្រាំង និងរដូវវស្សានៅក្នុងខេត្តបាត់ដំបង ។

An estimated 83% of Battambang’s annual rainfall is from the wet season. However, deviation from this pattern is quite common, having occurred in 1981, 1999, 2002, 2008 and 2017 where dry season rainfall was observed to have higher contribution, surpassing its average of 225 mm. Figure 2 indicates the variability of wet and dry seasonal rainfall in Battambang.




Figure B-2. Variability in wet and dry season contribution to annual rainfall

នៅក្នុងឆ្នាំ ១៩៨១ ភ្លៀងធ្លាក់នៅក្នុងរដូវប្រាំងគឺមានកម្រិតខ្ពស់ ៤៤%នៃភ្លៀងសរុបប្រចាំឆ្នាំ ស្របពេលដែលភ្លៀងធ្លាក់តិចបំផុតត្រូវបានបង្ហាញនៅក្នុងឆ្នាំ ២០០៤ ដែលមានកម្រិតទឹកភ្លៀងត្រឹមតែ ៧៣.៤ មីលីម៉ែត្រ (៧% នៃភ្លៀងធ្លាក់សរុបនៅក្នុងឆ្នាំ ២០០៤) ។ នៅក្នុងឆ្នាំ ២០១៤ ជាពេលដែលមានភ្លៀងធ្លាក់តិចបំផុត ដែលភ្លៀងនៅក្នុងរដូវប្រាំងមាន ៧៥០មីលីម៉ែត្រ និងរដូវវស្សា១២៨ ម.ល។

Highest contribution from the dry seasonal rainfall is observed in 1981 which accounts for 44% of total rainfall of the year, while lowest contribution is observed in 2004 with a contribution of just 73.4 mm (7% of total rainfall of 2004). In the year 2014, where the lowest rainfall for the period was recorded, the wet seasonal and dry seasonal contribution was 750 mm and 128 mm respectively.

Battambang has an average of 100 rainy days per year, out of which 18 are likely to occur in the dry season. During the considered period, the highest number of annual rainy days occurred in 1985 with a total of 122 rainy days while the lowest was recorded to be 77 days which occurred in 1998.

## ភ្លៀងធ្លាក់ច្រើនបំផុត

## 3. Rainfall Extremes

កម្រិតភ្លៀងខ្ពស់បំផុតប្រចាំថ្ងៃត្រូវបានកត់ត្រានៅក្នុងខេត្តបាត់ដំបងចាប់ពីឆ្នាំ ១៩៨១ ដល់ ២០១៧ ដូចដែលបានបង្ហាញនៅក្នុងតារាង ១ ។

The highest daily rainfall values recorded in Battambang for the period 1981-2017 are indicated below.

Table B-1. 24-hour extreme rainfall events of ≥100mm in Battambang

| **កម្រិតទឹកភ្លៀង** (Rainfall Amount) | **ថ្ងៃកត់ត្រា** (Date Recorded) |
|---|---|
| 170 mm | 19 May 1994 |
| 138 mm | 04 October 1990 |
| 109 mm | 13 April 1981 |
| 108 mm | 14 October 2010 |
| 102 mm | 23 April 2011 |
| 101 mm | 08 October 1995 |

## ការកើនឡើង និង ការព្យាករណ៍ទឹកភ្លៀង

## 4. Rainfall Trends and Projections

ភ្លៀងធ្លាក់ក្នុងរដូវវស្សា និងប្រចាំឆ្នាំបង្ហាញពីការថយចុះទាំងបរិមាណ និងចំនួនថ្ងៃភ្លៀងធ្លាក់នៅក្នុង ១៩៨១ដល់ ២០១៧ ។ ស្រដៀងនិងការថយចុះទឹកភ្លៀងត្រូវបានសង្កេតតាមរយៈភ្លៀងរដូវប្រាំង ទោះបីជាចំនួនថ្ងៃធ្លាក់ទឹកភ្លៀង នៅក្នុងរដូវប្រាំងបង្ហាញពីការកើនឡើងជាលក្ខណៈវិជ្ជមានក៏ដោយ ។

ប៉ុន្តែការកើនឡើងចំនួនថ្ងៃភ្លៀងនៅក្នុងរដូវប្រាំងនិងរដូវវស្សាគឺមិនមានភាពខុសគ្នា ។ ដូច្នេះការថយចុះនៃបរិមាណទឹកភ្លៀងត្រូវបានកំនត់នៅក្នុងខេត្តបាត់ដំបង។

Annual and wet seasonal rainfall indicates decreasing trend in terms of both quantity and number of rainy days for the period 1981-2017. Similar pattern of decreasing trend was observed for dry seasonal rainfall, although the number of rainy days in the dry season indicated a positive trend. However, the trends in the number of rainy days for both wet and dry season were insignificant. Therefore, a decrease in the quantity of rain is observed in Battambang. In contrast, the projections indicate an increasing trend as shown in the following figure[15].




**Figure B-3. Projected rainfall under RCP4.5 and RCP8.5**

នៅក្នុងករណីទាំង ២ ការកើនឡើងយ៉ាងខ្លាំងនៃទឹកភ្លៀងត្រូវបានរកឃើញនៅក្នុងឆ្នាំ ២០២១ ដល់ ២០៤០ ស្របពេលដែលការថយចុះនៃទឹកភ្លៀងត្រូវបានឃើញនៅក្នុង RCP4.5 និង គ្មានការផ្លាស់ប្តូរនៅក្នុងម៉ូដែល RCP8.5 ។

A potential increase in the rainfall is observed under both scenarios except for the period 2021-2040 where a decrease in rainfall is observed for RCP4.5 and no change is indicated for RCP8.5 relative to model baseline.

### សីតុណ្ហភាពជាមធ្យមប្រចាំខែ

### 5. Average Monthly Temperature

ពីព្រោះតែទិន្នន័យសីតុណ្ហភាពនៅមានកម្រិតការវិភាគត្រូវបានធ្វើឡើងសម្រាប់ឆ្នាំ ២០០៤ ដល់ ២០១៦ ។

សីតុណ្ហភាពពេលថ្ងៃខ្ពស់បំផុតនៅក្នុងខេត្តបាត់ដំបងត្រូវបានកើតឡើងនៅក្នុងខែមេសាដែលមានសីតុណ្ហភាពជាមធ្យម ៣៦.៣៩$^0$C និងសីតុណ្ហភាពពេលថ្ងៃទាបបំផុត ៣១.១០$^0$C ត្រូវបានកើតឡើងនៅក្នុងខែធ្នូ ។ នៅក្នុងករណីសីតុណ្ហភាពពេលយប់ សីតុណ្ហភាពខ្ពស់បំផុតនិងទាបបំផុត ២៥.៨៣$^0$C ដែលបានកត់ត្រានៅក្នុងខែឧសភា និង ២០.៦២$^0$C នៅក្នុងខែមករា ។ សីតុណ្ហភាពជាមធ្យមប្រចាំខែពេលថ្ងៃនិងពេលយប់ត្រូវបានបង្ហាញនៅក្នុងតារាងទី៤ ។

ពីព្រោះតែទិន្នន័យសីតុណ្ហភាពនៅមានកំណត់ ការវិភាគត្រូវបានធ្វើឡើងត្រឹមឆ្នាំ ២០០៤ ដល់ ២០១៦។

Since the availability of temperature data is limited the analysis was conducted for the period 2004 to 2016. Highest daytime temperature in Battambang is recorded in April with an average of 36.39$^0$C and the lowest daytime temperature is 31.10$^0$C recorded in December. In the case of nighttime

[15] Projections of rainfall in Battambang were obtained from downscaled NEX-NASA data for four 20-year time periods. These are presented under two scenarios of Representative Concentration Pathways (RCPs): RCP4.5 and RCP8.5. The values are obtained with reference to the model baseline for 1986-2005.
ការព្យាករណ៍ទឹកភ្លៀងនៅក្នុងខេត្តបាត់ដំបងត្រូវបានធ្វើឡើងដោយទិន្នន័យ NEX-NASA នៅក្រោមម៉ូដែលអាកាសធាតុរយៈពេល ២០ឆ្នាំចំនួន៤។ ការគណនាត្រូវបានបង្ហាញនៅក្រោមករណី ២ គឺ Representative Concentration Pathways (RCPs)*; RCP4.5 and RCP8.5 ដូចដែលបង្ហាញនៅក្នុងក្រាហ្វិកទី ៣ ។

temperature, highest and lowest recorded temperature are 25.83$^0$C recorded in May and 20.62$^0$C recorded in January respectively. The average monthly daytime and nighttime temperature as shown below.




ក្រាហ្វិក៤៖ សីតុណ្ហភាពពេលថ្ងៃ និងពេលយប់ជាមធ្យមនៅក្នុងខេត្តបាត់ដំបងនៅក្នុងឆ្នាំ ២០០៤ ដល់ ២០១៦

Figure B-4. Average daytime and nighttime temperature, 2004-2016

## សីតុណ្ហភាពខ្ពស់បំផុត

## 6. Temperature Extremes

សីតុណ្ហភាពខ្ពស់បំផុតនៅពេលថ្ងៃនៅក្នុងខេត្តបាត់ដំបងត្រូវបានប្រមូលនៅថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦ ដែលមាន ៤១.១$^0$C ។ នៅក្នុងឆ្នាំនោះ សីតុណ្ហភាពខ្ពស់ជាង ៣៥$^0$C មានចំនួន ៩៦ថ្ងៃ និង ៤៦ថ្ងៃមានសីតុណ្ហភាពខ្ពស់ជាង ៣៨$^0$C និង ៩ថ្ងៃទៀតមានសីតុណ្ហភាពខ្ពស់ជាង ៤០$^0$C ។ តារាងទី ៤បង្ហាញពីបម្រែបម្រួលនៃចំនួនថ្ងៃដែលមានសីតុណ្ហភាពខ្ពស់ជាង ៣៨$^0$C ។

The highest daytime temperature in Battambang was recorded on 11$^{th}$ of April 2016 at 41.1$^0$C. This year indicated to have 96 days with temperature higher than 35$^0$C, 46 days with temperature greater than 38$^0$C and 9 days with temperature greater than 40$^0$C. Figure 4 indicates the variation of number of days with temperature higher than 38$^0$C.




ក្រាហ្វិក៤៖ សីតុណ្ហភាពក្តៅដែលធំជាង ៣៨អង្សារសេនៅក្នុងខេត្តបាត់ដំបង

Figure B-5. Extreme daily temperature of >38$^0$C in Battambang

សីតុណ្ហភាពពេលថ្ងៃត្រជាក់បំផុតគឺ ២៨$^0$C ដែលត្រូវបានប្រមូលក្នុងពេលវេលា២ ផ្សេងៗគ្នាគឺ ថ្ងៃ ៥ខែមករា ២០០៨ និង ថ្ងៃទី ៣ ខែ វិច្ឆិកា ២០០៩ ។ សីតុណ្ហភាពពេលយប់ខ្ពស់បំផុតគឺ ៣០.៤$^0$C ថ្ងៃ ៣ ខែ មេសា ២០០៨ ។ ចំនួនយប់ដែលពេលមានសីតុណ្ហភាពខ្ពស់ជាង ២៥$^0$C ច្រើនជាងគេត្រូវបានកើតឡើងនៅក្នុងឆ្នាំ ២០១៥ ដែលមានចំនួន ២១៣យប់ ស្របពេលដែលនៅក្នុងឆ្នាំ ២០១៦ មានត្រឹមតែ ២០៦យប់ប៉ុនោះ។ នៅក្នុងរយៈ ២ឆ្នាំនោះតែប៉ុនោះគឺឆ្នាំ ២០០៤ ដល់ ២០១៦ ចំនួនយប់ដែលមានសីតុណ្ហភាពខ្ពស់ជាង ២៥$^0$C មានចំនួនច្រើនជាង២០០យប់ ។ យប់ដែលមានសីតុណ្ហភាពត្រជាក់ជាងគេនោះគឺមានសីតុណ្ហភាព ១១.៨$^0$C នៅថ្ងៃ ២៣ ខែ ឧសភា ២០១៦ ។

Coolest daytime temperature was recorded at 24$^0$C, observed on two occasions, 5$^{th}$ January 2008 and 3$^{rd}$ November 2009. On the other hand, the highest nighttime temperature was 30.4$^0$C on 3$^{rd}$ April 2008. Highest number of nights with temperature greater than 25$^0$C was in 2015 with 213 nights followed by 2016 with 206 nights. Only these 2 years have had more than 200 nights with temperature higher than 25$^0$C for the period 2004-2016. The coolest nighttime temperature recorded was 11.8$^0$C on 23$^{rd}$ May 2016.

## ការកើនឡើង និងការព្យាករណ៍សីតុណ្ហភាព

## 7. Temperature Trends and Projections

